ការសម្ភាសរបស់កុង ខ្ចាយ សិរី

ក៖ អ្នកសម្ភាសឈ្មោះ ជាង ស៊ីអ៊ាវ *ខ៖ អ្នកត្រូវគេសម្ភាសឈ្មោះ ខ្ចាយ សិរី*

ការសង្ខេបប្រវត្តិរបស់កុងខ្ចាយ សិរី

កុង (តា) ខ្ចាយ សិរីមានអាយុ ឆ្នាំនៅក្នុងឆ្នាំ២០២០ ភេទសប្រុស មានលំនៅបច្ចុប្បន្ននៅភូមិឡឥដ្ឋ ឃុំបឹងកុក ស្រុកកំពង់ចាម ខេត្តកំពង់ចាម។

ក៖ មានស្អីឆ្លើយទៅបាទចឹងជាដំបូងខ្ញុំអរគុណច្រើនកុងដែលបានឱ្យខ្ញុំពិភាក្សាជាមួយកុង?

ខ៖ បាទ!

ក៖ ទាក់ទងពីប្រវត្តិរបស់កុង ហើយការសម្ភាសទាំងអស់ហ្នឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU?

ខ៖ បាទ!

ក៖ ហើយដោយសារតែសាកលវិទ្យាល័យ មានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកឱ្យកូនចៅជំនាន់ក្រោយៗ ពួកគាត់បានស្គាល់ហ្នឹងបានដឹង ជាពិសេសប្រវត្តិរបស់កុងទុកឱ្យកូនៗរបស់កុង ឬ មួយក៏ចៅៗរបស់កុងបានស្គាល់បានដឹង។ ចឹងសម្រាប់កុងយល់ព្រមដើម្បីឱ្យខ្ញុំដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយសាលាទេកុង?

ខ៖ បាទ!

ក៖ បាទ! ចឹងសម្រាប់ខ្ញុំជាអ្នកសម្ភាសកុងខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែលខ្ញុំសម្ភាសកុងគឺនៅថ្ងៃទី២៨ខែ៧ឆ្នាំ២០២០?

ខ៖ បាទ!

ក៖ ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងនៅភូមិឡឥដ្ឋ ឃុំបឹងកុក ស្រុកកំពង់ចាម ខេត្ត កំពង់ចាម។ ចឹងសម្រាប់កុងឈ្មោះពេញរបស់កុងតាមបញ្ជីជាតិហាសឈ្មោះអីគេកុង?

ខ៖ ឈ្មោះខ្ញុំហោសឥឡូវវាចេះឈ្មោះខ្ញុំខ្មាយសិរី។

ក៖ ខ្មាយ សិរី?

ខ៖ បាទ! ហើយកាលខ្ញុំរៀននៅតូចៗដែរ គេជេរខ្ញុំតែអាខ្មាយទេ។

ក៖ អ៎ូ!

ខ៖ បាទ!

ក៖ អាហ្នឹងឈ្មោះកុង..?

ខ៖ ឈ្មោះពិតប្រាកដរបស់ខ្ញុំ។

ក៖ ឈ្មោះក្នុងបញ្ជីជាតិម៉ងហោសកុង?

ខ៖ បាទបញ្ជីជាតិបាទ!

ក៖ អើខ្មាយសិរី?

ខ៖ បាទ!

ក៖ ប៉ុនឥឡូវគាត់..?

ខ៖ ដល់ជំនាន់ប៉ុលពតគេជម្លៀសខ្ញុំទៅនៅដំបែហ្នឹង។

ក៖ ចា៎ស!

ខ៖ អើឮអើចឹងណា៎។

ក៖ ចា៎ស!

ខ៖ ដោយសារវាគ្មានមិត្តភក្តិខ្ញុំ។

ក៖ ចាស!

ខ៖ មុនដំបូងខ្ញុំអត់ជឿទេ ៧៣យើងហ្នឹងគេវាយកំពង់ចាមអើ៧២គេវាយកំពង់ចាមបែក។

ក៖ ចាស!

ខ៖ ប៉ុនខ្ញុំរត់ទៅភ្នំពេញរត់ទៅភ្នំពេញអាពូកម៉ាកខ្ញុំវានៅទូលស្បូវហោស។

ក៖ បាទកុង!

ខ៖ អើវាលវង់នេះវាលវង់ក្រោយពេទ្យហ្នឹង។

ក៖ បាទៗកុង!

ខ៖ ពូកអាពតហ្នឹងវាយកំពង់ចាម៧២ហ្នឹងកៀរយកទៅទៅនៅកងមាស។

ក៖ ចាស!

ខ៖ ដល់កងមាសទៅអើខ្ញុំនេះចិតពីរមានជីដូនជីតាខ្ញុំអើមិនអួតទេសុទ្ធតែអ្នកធំហាសណាស់។

ក៖ បាទកុង!

ខ៖ អើតាអុលជ័យសំអុលអាហ្នឹងជាប្អូនពៅជីដូនខ្ញុំ។

ក៖ បាទកុងបាទ!

ខ៖ គាត់ពាក់សក្តិប្រាំខាងកាន់ខាងភូមិសាស្ត្រហាសខាងកងទ័ពខាងផែនទីភូមិសាស្ត្រកងទ័ពហាស។

ក៖ បាទកុង!

ខ៖ ដល់៧២ហ្នឹង គេវាយបែក បែកកំពង់ចាមគាត់ឱ្យយន្តហោះអាលិកកូហាសមកដឹកមួយពូជខ្ញុំហ្នឹងទៅ។

ក៖ បាទ!

ខ៖ ប៉ុន្តែដោយសារដូចមនុស្សដណ្តើមឡើងយន្តហោះច្រើនពេកគាត់ឱ្យយកបងគាត់យាយខ្ញុំ ហ្នឹងហាស យាយបាចហ្នឹងហាសប្រាំងបាចហ្នឹងហាស។

ក៖ បាទតា!

ខ៖ ហើយប្អូនស្រីខ្ញុំមួយទៅហើយបានប្រហែលជាមួយអាទិត្យគាត់អត់សុខចិត្តទេ។ គាត់ដេញក្ងួយគាត់មួយ ក្ងួយហ្នឹងគាត់ត្រូវជាឪពុកក្ងួយគាត់ហ្នឹងជាប្រាំងគល់អើប្រាំងតាគល់អើតាគួងប្រាំងគួង។

ក៖ បាទកុង!

ខ៖ គាត់ក៏ជាមេទាហ៊ានដែរ តាំងពីជំនាន់អ៊ីសារ៉ាក់ជំនាន់សម្តេចឪហ្នឹងហាសសម្តេចឪហ្នឹងហាស។

ក៖ បាទកុង!

ខ៖ គាត់ប៉ុនគាត់ស្លាប់ទៅស្លាប់ប្រហែលទំនងជំនាន់អើគណៈបក្សប្រជាធិបតេយ្យក្បាលដំរីហ្នឹងហាស។

ក៖ បាទកុង!

ខ៖ គាត់ស្លាប់ទៅបាននៅពូតូចខ្ញុំហៅពូតូច។

ក៖ បាទកុងបាទ!

ខ៖ អើតាគួងណុងខ្ញុំមិនដែលស្គាល់មុខទេ ស្គាល់ពូតូចពូតូចហ្នឹងគាត់ធ្វើទាហ៊ានម៉ារីន។

ក៖ បាទកុង!

ខ៖ គាត់សក្តិពីរបាទគាត់សក្តិពីរហាសអើសក្តិពីរម៉ារីនហាស។

ក៖ បាទកុង!

ខ៖ តាអុលហ្នឹងគាត់ដេញពូតូចហ្នឹងឱ្យមកយកគ្រួសារខ្ញុំមួយពូជហ្នឹងគាត់ទាក់ទងខ្ញុំទៅឱ្យខ្ញុំទៅម្តាយខ្ញុំៗប្អូនខ្ញុំ៩នាក់។

ក៖ ចឹងហោសកុង?

ខ៖ ទាំងអស់៩នាក់បងប្អូនខ្ញុំរួចទៅហើយខ្ញុំហ្នឹងក៏ទៅភ្នំពេញទៅ។

ក៖ បាទកុង!

ខ៖ អាជិះម៉ារីនណុងហាស។

ក៖ បាទកុង!

ខ៖ អើជិះម៉ារីនទៅដល់ភ្នំពេញទៅអើខ្ញុំទៅដល់ភ្នំពេញអាមិត្តភក្តិដែរ ខ្ញុំនៅកងមាសហ្នឹងគេកៀរអោពតគេកៀរវាទៅនោះ។

ក៖ បាទកុង!

ខ៖ វាសុំគេមកប្តូរស្បៀងណាខាងស្រែនេះយកដំឡូងមកដូរស្រូវ។

ក៖ បាទ!

ខ៖ ប៉ុនដល់ទទួលវាឃើញចឹងឃើញម៉ារីនវានៅកោះប្រាក់អើកោះយើងនេះកោះគល់កោះយើងអីនេះ។

ក៖ កោះគល់បាទ!

ខ៖ បាទឃើញតែហ្នឹងអើហៅអីអន្លង់ស។

ក៖ បាទកុង!

ខ៖ វាទម្លាក់កង់ចុះសុំគេបត់ជើងប៉ុនវាទម្លាក់កង់ចុះវាអង្អែលកងម៉ារីនមក។

ក៖ បាទកុង!

ខ៖ ដល់ម៉ារីនមកវាអាពួកម៉ារីនចាប់វាថាវាជាពួកខ្មែរក្រហម។

ក៖ បាទកុង!

ខ៖ ហៅលទន្លេមកដាក់គ្រាប់បែកប៉ុនអាហ្នឹងឈ្មោះទីឆៃហឿន អាទីឆៃហឿនហ្នឹងវាថាកុំធ្វើបាបខ្ញុំ។ ខ្ញុំជាកូនសិស្សសាលារៀនសាលាតិចនិចបឹងកុកនេះជំនាន់ចិតសិបចិតមួយចិតពីររៀនជាមួយគ្នាហ្នឹងហាស។

ក៖ បាទកុង!

ខ៖ រៀនថ្នាក់ជាមួយកុងនេះ ប៉ុន្តែឥឡូវគេវាយធ្វើដាក់ជាវិទ្យាល័យ..។

ក៖ បឹងកុក?

ខ៖ បឹងកុកហ៊ុនសែនហើយ។

ក៖ បាទកុង!

ខ៖ កាលមុនហៅមហាវិទ្យាល័យយួនវិទ្យា។

ក៖ បាទកុង!

ខ៖ ណុងហាសសាលាបឹងកុកហ្នឹងហាស។

ក៖ បាទកុង!

ខ៖ ប៉ុនឥឡូវគេវាយអាសាលាខ្ពស់ចោលគេធ្វើអាសាលាថ្មីហើយ។

ក៖ បាទកុង!

ខ៖ អើរួចទៅដល់ពេលហ្នឹងខ្ញុំជួបវាទៅនាំទ័ពម៉ារីនហ្នឹង វាថាកុំប្រើអើវាថាកុំធ្វើបាបខ្ញុំខ្ញុំកូនសិស្សរៀនសាលាហ្នឹងទេ។ បើមិនជឿសួរបងមួយថាដូចយើងឆ្នាំទីមួយទីពីរចឹងហាស។

ក៖ បាទកុងបាទ!

ខ៖ អ្នកឆ្នាំទី៣ហ្នឹង គេចេញពីសាលាទៅគេចូលធ្វើម៉ារីនហ្នឹងដែរ។

ក៖ បាទកុង!

ខ៖ គេមានឧទេសនាមទេសស្រែង ឈ្មោះទេសស្រែងអាហ្នឹងពេលហ្នឹងហាស។

ក៖ បាទកុង!

ខ៖ រួចអាឆៃហៀនហ្នឹង វាទៅម៉ារីនហ្នឹងកុំធ្វើបាបខ្ញុំបើមិនជឿសួរបងទេសស្រែងទៅខ្ញុំកូនសិស្សទេ ស្រាប់តែវានាំអាពួកហ្នឹងនាំវាទៅដល់ម៉ារីនហើយតាមម៉ារីនហ្នឹងហាស។

ក៖ បាទកុង!

ខ៖ រួចបងស្រែងហ្នឹងសួរថាវាថាតាឯងម៉េចបានស្គាល់អញច្បាស់ម៉េស អាមួយហ្នឹងហាស ទៅមើលឃើញវាមែនអាឆៃហៀនមែន។ គាត់ធានាឈប់ឱ្យនៅហ្នឹងហើយកុំឱ្យគេដាក់គុកវាណា៎។

ក៖ បាទកុង!

ខ៖ លែងវាទៅនៅភ្នំពេញទៅដល់ខ្ញុំដើរជួបវាទៅវានិយាយប្រាប់រឿងហ្នឹងហាស។

ក៖ បាទកុង!

ខ៖ ប៉ុនដល់រួចថាហែងបើធ្វើទាហ៊ានធ្វើការរដ្ឋបិការគ្រូបង្រៀនស្អីក៏ដោយកុំនិយាយពេលណាខ្មែរក្រហមវាយហែងឈ្នះហើយគឺវាសម្លាប់ហែងចោលហើយ។

ក៖ ចឹងហោសអ៊ុំ?

ខ៖ ពួកហែងចោលហើយខ្ញុំថាហែងគួរនិយាយអីថាហាសអញមិនជឿទេ គេធ្វើបដិវត្តន៍មួយទាំងមូល។ គេជួយប្រជារាស្ត្រមែនធ្វើបដិវត្តន៍សម្លាប់មនុស្សណា ហើយចាំមើលទាំងអស់គ្នាទៅថាចឹងហា។ កាលណុងវាជុំគ្នាញ៉ាំស៊ុបអីចឹងហាស មកជួបគ្នាបែកគ្នាហៅញ៉ាំស៊ុបទៅវានិយាយរឿងប្រវត្តិថានិយាយរឿងថាកុំធ្វើយើងធ្វើទាហ៊ានធ្វើអីចឹង កុំប្រាប់គេចឹងហាសណា៎។

ក៖ បាទកុងបាទ!

ខ៖ ដល់ពេលណាងក៏ខ្ញុំនិយាយវាថាហែងគេធ្វើបដិវត្តន៍ទាំងអស់គ្នា យើងក៏ធ្វើបដិវត្តន៍ទាំងអស់គ្នាជាមួយគ្នាតើកវែងធ្វើបដិវត្តន៍ដើម្បីប្រជាជនចម្រើនហីម៉េចបានទៅសម្លាប់គ្នាចោល ថាបើមិនជឿចាំមើលទៅដល់៧៥វាយគ្នាហ្នឹងចូលភ្នំពេញម៉ោង៨មិនទាន់អីទេណា៎បង។

ក៖ ចា៎ស!

ខ៖ អ៎ូក្មេងៗទេប្រហែលជាដប់ពីរដប់បីស្តាយកាំភ្លើងដែងអាកាកាន់អូសដីតើ។

ក៖ បាទកុង!

ខ៖ ខោខ្លីដើរគ្នាហាត់ហោសរួចបើមេប្រហែលជាអាយុម្តែ ម្តែពីរអីអាស្តរខ្ញុំក្មេងៗហ្នឹងហាស។

ក៖ បាទកុង!

ខ៖ ដើរអើពួកហ្នឹងចូលមកដំបូងអត់អីទេ អ្នកស្រុកយើងឃើញចឹងហាសឃើញវាដើរមកហាត់បែកញើសអីដូចក្មួយអីចឹងហាស។

ក៖ បាទកុង!

ខ៖ ដាក់ផ្តិលទឹកប្រាក់សុទ្ធផ្តិលទឹកប្រាក់អីទៅអើខ្ញុំនៅផ្សារដើមគរហោស។

ក៖ អ៎ូ!

ខ៖ ដាក់ទទួលហោសខ្ញុំធ្វើជាងមាសដែរហោស។

ក៖ បាទកុង!

ខ៖ រួចគាត់ណាងផ្ទះណាងប្រហែលធ្វើកុងស៊ីដាក់ទទួលគ្នាអាខ្លះផឹកអាខ្លះស្អីទៅដើរទៅទៀតទៅ។

ក៖ ចា៎ស!

ខ៖ ណោះអាហ្នឹងក្រោយហោសមកទះដេញចេញម៉ង រួចដល់ខ្ញុំឃើញចឹងខ្ញុំទៅប្រាប់ប៉ាខ្ញុំ ប៉ាខ្ញុំថាពួកអើយណោះគេដេញចេញយើងពីភ្នំពេញហើយអើឈប់នៅភ្នំពេញហើយគាត់នរណា

ដេញហែងចេញដូចកំពង់ចាមទៀតទេហាស ទៅនៅណាវាលស្រែហេសអត់ជឿដល់ចឹងនាំគ្នាខ្ជប់ទ្វារខ្ជប់ទ្វារអង្គុយហាសណា៎។

ក៖ ចា៎ស!

ខ៖ ម៉ោង៧ ម៉ោង៨ អើម៉ោង៩វាដល់ហាសណា៎ រួចអង្គុយស្តាប់វិទ្យុស្តាប់វិទ្យុកាលណុងវិទ្យុនៅផ្សាយទេណា៎ម៉ោងប្រាំបីប្រាំបួនហាស។

ក៖ បាទ!

ខ៖ កាលណុងលោកអើម៉ែស៊ីចនអើស៊ីសែខុនរត់ឡើងយន្តហោះបាត់ហើយឡើងនៅម៉ែស៊ីចនតំណាងហាស។

ក៖ បាទកុង!

ខ៖ រួចលោកសង្ឃលោកតាចាំងថាន។

ក៖ បាទកុង!

ខ៖ តំណាងសង្ឃហាស។

ក៖ បាទ!

ខ៖ ហើយលោកសេរីម៉តាក់លោកបូរ៉ែតអីហ្នឹងហាសតំណាងអើរដ្ឋាភិបាលហ្នឹងហាស។

ក៖ បាទកុង!

ខ៖ មកចាំទទួលចឹងខ្ញុំស្តាប់តាមវិទ្យុទេណា៎ គេផ្សាយហាស។

ក៖ បាទៗ!

ខ៖ ចាំទទួលគាត់ចាំទទួលពួកខ្មែរក្រហមហាស។

ក៖ បាទ!

ខ៖ ដល់ពេលហ្នឹងគាត់វាចូលមកចូលមកវាមែននេះណា គេថាឈ្មោះកេតដាវ៉ា យើងកេតដាវ៉ាមិនមែនមកចរចាទេគឺមកដោយឈ្នះដោយចុងកាណុងកងបដិវត្តន៍យកឈ្នះ ដោយចុងកាណុងអើហើយយើងជាកេតដាវ៉ាទៅដាក់រឿងបាត់ទៅហើយបានម៉ោង១១ហាស។

ក៖ ចាស!

ខ៖ អើចេះតែអង្គុយស្តាប់ទៀតទៅ ដល់ម៉ោងបីមកគោះទ្វារពោកៗអើយពូមីងបងចេញក្រៅតើវាចង់ទម្លាក់គ្រាប់បែក។

ក៖ អើ!

ខ៖ មានអីមានយកអីទេ រួចអាណាយកអើបើកកុងស៊ីប្រចាំអាណាគេយកឱ្យអ្នកស្រុកយើងពីដើមហោស។

ក៖ ចាស!

ខ៖ ចាំអត់មានយកអីទេទុកសឹងអស់អង្ករក៏មិនយកជាចាក់អោយជ្រូកស៊ីអើយើងចិញ្ចឹមជ្រូកហោស!

ក៖ ចាស!

ខ៖ យកប្រហែលជាមួយតៅអង្ករដាក់ហ្នឹងកង់រួចកង់ណាកង់ចឹងហាសបីបួន កាលណុងវាសំណាងដោយសារកង់ដែរ មិនពិបាកលីសែងទូលរែកអីទេណា៎។

ក៖ បាទកុងបាទ!

ខ៖ អាប្អូនខ្ញុំអាពៅតូចជាងហ្នឹងទេបីឆ្នាំ អានេះអាទីប្រាំទីបួនទីអីហ្នឹងវាតូចហោសអត់ឱ្យហែងដើរទេ។

ក៖ ចាស!

ខ៖ ខ្លាចវាដើរទៅដឹកដាំចូលទ្បានដាច់ដៃពីគ្នារបូតដៃពីគ្នាចឹងហាស។

ក៖ ចាស!

ខ៖ ហែងលើកង់អង្គុយលើកង់ហែងឈឺនោមហែងនោមដាក់កង់ទៅដាក់កង់ទៅពន្លិចអើសុទ្ធប្រុសៗហោស។

ក៖ ខ្លាចបាត់ប្អូន?

ខ៖ ខ្លាចប្អូនខ្លាចបាត់ប្អូនម្តាយខ្ញុំចាស់ដែរហើយ។

ក៖ ចាស!

ខ៖គាត់មិនសូវមាត់ករទេ ខ្ញុំចេះតែសម្តែតគំរាមកំហែងទៅណា។

ក៖ ចាស!

ខ៖ ចេះតែទៅរួចមកតាមផ្លូវរហូតហូរហែមកយកទៅនៅតំបែហោស។

ក៖ អ៎ូ!

ខ៖ ចុះយើងចេះពីផ្សារដើមគរមក តាមផ្លូវជាតិលេខពីរដល់អើវិទ្យាល័យសំរោងយោងឃើញវិទ្យាល័យអស់រលីងនៅតែឃ្លោងទ្វារ ខ្ញុំចេញមកនៅតែស្រណោះរួចផ្ទះណុងតាមផ្លូវធំៗដែរណា។

ក៖ បាទ!

ខ៖ ទៅប៉ែកអីលិចណុងឆេះអស់ហើយមានផ្ទះអ្នកស្រុកល្អៗទេ។

ក៖ អ៎ូ!

ខ៖ ដល់សំរោងយោងហ្នឹងឃើញតែឃ្លោងទ្វារសំរោងយោងហ្នឹងទេ អង្គុយខ្ញុះក្តាមយកមកហូប។

ក៖ ចាស!

ខ៖ ដល់រួចទៅគេចេះតែដេញចេញអើដល់ថាមកដល់សួង ដល់ជើងលងដែរ ស្រុកកំណើតខ្ញុំពីតូចហោស។

ក៖ បាទកុង!

ខ៖ គាត់ថាអាគេអ្នកស្រុកណុងគាត់គេះឪពុកខ្ញុំរួចខ្ញុំឈរស្តាប់ថាអើទ្រាំឯងកុំនៅៗគេស្គាល់គ្នាចឹងស្គាល់គ្នាចឹងមិនអោយនៅទេ។

ក៖ បាទកុង!

ខ៖ ខ្លាចគេយកវាយចោលណុង។

ក៖ ចាស!

ខ៖ គាត់ថាឥឡូវនៅសម្រានផ្ទះខ្ញុំមួយយប់ហោសចាំព្រឹកឡើងធ្វើរត់ឡើងរទេះម៉ងទៅសួរអើកុំឱ្យប្រាប់ទេ កុំទៅនៅខាងមេម៉ត់ខាងអីខ្លាចចាញ់ទៅខាងតំបែមិនសូវចាញ់។

ក៖ ចាស!

ខ៖ មានអីខ្ញុំធ្វើអ៊ូរត់ដែរ ពូៗខ្ញុំទៅខាងតំបែផ្ទះខាងតំបែលក្ខណៈរទេះទៅបាត់ទៅ។ អ៊ូ! អង្គុយរទេះធម្មតាអាមនុស្សយើងមិនដែលជិះគ្រាន់តែអង្គុយខ្លីងខ្លងពុលក្អួត។

ក៖ ខ្លីងខ្លោងហោស?

ខ៖ អើពុលដូចពុលរលកចឹងលេងពុលយន្តហោះចឹងហាស ជិះយន្តហោះថាពុលជិះរទេះគោក៏ពុលដែរ។

ក៖ អ៊ូ!

ខ៖ អាហ្នឹងប្រវត្តិមួយសារចេញពីភ្នំពេញ។

ក៖ ចាស!

ខ៖ បាទអាហ្នឹង!

ក៖ បាទ! ពេលចូលប៉ុលពតហោសកុង?

ខ៖ បាទ! ទៅប៉ុលពតខ្ញុំទៅនៅតំបែហោស។

ក៖ អ៎ូ!

ខ៖ បាទរួចទៅដល់ប៉ុលពតគេនិយាយថាឈ្មោះអីៗចឹងហាសខ្ញុំថាខ្ញុំនៅរៀនទេ រួចពុកមាត់ចេះតែលួចយកកន្ត្រែកាត់ហ្នឹងឡាមកោរទៅកាំបិតកាត់លួចដកទៅខ្ញុំថាខ្ញុំនៅរៀនទេ រួចបានខ្ញុំដូរឈ្មោះហ្នឹងហោសរួចឈ្មោះខ្ញុំបានដាក់..។

ក៖ គ្រូអយរីហ្នឹងវិញទៅ?

ខ៖ ដាក់គ្រូអយរីតាំងពីជំនាន់ណុងមក។

ក៖ អ៎ូ!

ខ៖ ប៉ាខ្ញុំប្តូរឈ្មោះខ្មាយសិរីហ្នឹង ដូរមកអយរីហាសតាំងពីជំនាន់ប៉ុលពតណុងមក។

ក៖ បាទ!

ខ៖ រហូតមក។

ក៖ អ៎ូ!

ខ៖ ចឹងហាស!

ក៖ ប៉ុន្តែបើថាឈ្មោះកុងម៉ងគឺខ្មាយសិរី?

ខ៖ បាទ! ខ្មាយសិរីទេ។

ក៖ អ៎ូ! បាទកុងបាទចឹងមានន័យថាឈ្មោះក្រោយហ្នឹងឈ្មោះអូរីហ្នឹងឈ្មោះ..?

ខ៖ អយរី។

ក៖ អយរីហោសកុង?

ខ៖ ខ្ញុំយកត្រកូលឪពុកខ្ញុំវិញ។

ក៖ អ៎ូចឹងណោះកុង?

ខ៖ ណាយតាណាយៗហ្នឹងគាត់នៅកោះសូទិនឈ្មោះតាណាយ ប៉ុន្តែទំនងស្តាប់ទៅថាលោកទំនងមេឃុំណុងស្តាប់មិនបានដាក់ខ្នាយទៅតាមពិតហៅតាណាយទេហ្ន៎ដាក់ស្រះអាហ្នឹងយកគេ។

ក៖ បាទកុងបាទ!

ខ៖ បាទប៉ុនដល់មេឃុំសរសេរខ្នាយខ្នាយទៅ។

ក៖ អ៎ូ!

ខ៖ ចឹងហាស!

ក៖ បាទ! កុងបាទ ប៉ុន្តែអើកុងគិតថាចឹងឈ្មោះមានតែពីរហ្នឹងទេណោះកុងណោះ?

ខ៖ បាទ!

ក៖ គ្មានឈ្មោះផ្សេងទេណោះកុង?

ខ៖ បាទ! មកដល់ពេលចេញពីតំបែមកចិតប្រាំពីរអានិរ តីនៅវ៉ែតំបែហោស!

ក៖ ថ៎ាស!

ខ៖ ជម្លៀសចេញពីតំបែមកវិញមកដល់ចុងក្រងហ្នឹងហោសជួបប្រពន្ធខ្ញុំហ្នឹង។

ក៖ ថ៎ាស!

ខ៖ ប្រពន្ធខ្ញុំបងប្អូនជីដូនមួយគ្នាទេម្តាយហ្នឹងដាក់..។

ក៖ អ៎ូ! ចឹងលោកគ្រួយកប្រពន្ធក្រោយហ្នឹងហោស?

ខ៖ បាទ! ខ្ញុំម្តាយខ្ញុំវាហ្នឹងបងប្អូនបង្កើត។

ក៖ ចាស!

ខ៖ បាទ! រួចទៅដល់ពេលជំនាន់ណុងឆ្នាំ៧៨ហ្នឹង គេថានរណានៅលីវឱ្យយកធ្វើទ័ពវា។

ក៖ បាទកុង!

ខ៖ រួចម៉ែខ្ញុំយំស្រែកគាត់ថាហែងយកប្រពន្ធទៅថាខ្ញុំថាអើមិនដឹងយកពីណាៗមិនស្គាល់គេមិនស្គាល់ឯងផង គាត់ថាយកបងប្អូនឯងទៅយើងដាច់ចិត្តហាសណា៎ បើមិនយកទេវាចាប់យើងយកធ្វើទ័ព។

ក៖ ធ្វើទ័ពបាទ!

ខ៖ ធ្វើទ័ពទៀតហើយ។

ក៖ ចាស!

ខ៖ ក៏សុខចិត្តការទៅដល់៧៩ ដាច់៧៩ណុង គេបោះឆ្នោតរើសប្រធានភូមិនោះ ប្រធានភូមិចាត់តាំងឱ្យខ្ញុំធ្វើគ្រូបង្រៀនតាំងពីណុងមក។

ក៖ ចាស!

ខ៖ ពី៧៩មកដល់៨៣បានមូលហេតុ៨៣ខ្ញុំមកកំពង់ចាមហ្នឹងវិញ ប្រពន្ធខ្ញុំនេះខ្ញុំតេអា៧៩-៨០ដែរហ្នឹង គេមិនប្រាក់ខែគ្រូមានហើយបួនដប់ម្តែរៀនហ្នឹងហាស។

ក៖ ចាស!

ខ៖ ក្តាបមិនដឹងចាយម៉េចកើតទៀតហ្នឹងហាសទំនងនៅណុងហាស។

ក៖ ចាស!

ខ៖ អើល្មមចេញពីចុងក្រោមមកផ្សារស្លងបានបានចាយរួចដើរកាត់វាលក៏ពិបាកអីពិបាកនៅណុងអញមិនចេះនៅទេប្រពន្ធថាចឹងហាស រកទៅធ្វើការឱ្យគេឮថាគេរើសគ្រូកំពង់ចាម។

ក៖ ហ្នឹងហើយ!

ខ៖ ក៏មកគេកាន់កាតសិស្សគេពីដើមហោសសាលា១៨មិនាហោស។

ក៖ បាទកុង!

ខ៖ រៀនថ្នាក់ទីបញ្ចប់គេមកបង្ហាញលោកឡៃសុខាចឹង លោកឡៃសុខាប្រធានមន្ទីរនៅហ្នឹងហាស។

ក៖ បាទកុង!

ខ៖ គេមកប្រាប់ថាគេរៀនបានថ្នាក់នេះៗសុំមកធ្វើគ្រូ។

ក៖ ចា៎ស!

ខ៖ គេឱ្យធ្វើភ្លាមធ្វើគ្រូប្រាំពីរបួកមួយជំនាន់ចិតពីរចិតបីហ្នឹងហាស។

ក៖ ចា៎ស!

ខ៖ បាទ! ចិតពីរចិតបីទៅរៀនទៅដល់គេត្រឡប់មកវិញ គេអត់ឱ្យទៅគេអត់ឱ្យទៅគេថាយើងជាគ្រូរើសដំបូង ហើយជាគ្រូគំរូប្រាំពីរបួកមួយឱ្យនៅកំពង់ចាមហ្នឹងហើយ។

ក៖ អ៊ូ!

ខ៖ សួរថាប្តីនៅណាថាប្តីនៅចុងក្រោមនោះធ្វើការនៅចុងក្រោមធ្វើអីធ្វើគ្រូអើបើធ្វើគ្រូឱ្យផ្លាស់មកផ្លាស់មកវិញមកផ្លាស់មកកំពង់ចាមមក។ ខ្ញុំសុំគេផ្លាស់មកកំពង់ចាមដែរទៅរួចប្រាប់គេថាខ្ញុំអត់មានដីមានផ្ទះនៅទេ៨៣ហ្នឹងផ្សារគេនៅអស់ហើយ។

ក៖ បាទកុង!

ខ៖ មានគេនៅអស់ហើយនៅចន្លោះដីៗមួយឡូៗចេះៗទេណា៎។

ក៖ បាទកុង!

ខ៖ ដល់នរទៅខ្ញុំថាគេថានេះដីហ្នឹងខ្ញុំនៅមុនហោសដីក្បែរសាលាទក្សិណហ្នឹងហាស។

ក៖ បាទកុងបាទ!

ខ៖ គេឱ្យទៅនៅដីណុងទៅ។

ក៖ អ៎ូ!

ខ៖ រួចជំនាន់ណុងចែកអើអាកូនខ្ញុំអា៣នាក់ហ្នឹងតូចៗផងអីផងនោះសង់តៀមនៅក្បែរសាលាណុងទៅស្រួលម៉ែច ទៅគ្រូបង្រៀនផងទៅបំបៅកូននៅណុងទៅ។

ក៖ អ៎ូ!

ខ៖ រួចលក់នំលក់ណែកអីទៅបានហូបចេះតេកតាកៗទៅកាលកម្សត់កម្រយើង។

ក៖ ប៉ុនជំនាន់ប៉ុលពតលោកគ្រូពិបាកដែរហោស?

ខ៖ អ៎ូ! ជំនាន់ប៉ុលពតហោស បើនិយាយជំនាន់ប៉ុលពតវិញហោសខោអាវដែរយើងចេញពីភ្នំពេញទៅប៉ុន្មានមានប៉ុន្មានស្លៀកទៅរហែករហុយអស់ទៅមានមួយបំផ្លាស់ក្នុងខ្លួនទេ។ កាលណុងដូចមានពីរកំភ្លេដែរ ប៉ុនមួយកំភ្លេណុងរហែករហុយអស់ទៅស្លៀកមួយកំភ្លេអត់មានក្រម៉ាមុជទឹកអីទេ អើយកទៅដល់ណុងរបៀបដូចថាចុះវាដូចពិបាកវេទនាពេកខឹងវាពេកស្អប់វាពេកធ្វើអាវិធីមួយគឺថ្ងៃត្រង់មុជទឹកណុងក្តៅស្អុះហោស។

ក៖ ចាស!

ខ៖ ស្រាតខោអាវអស់មុជទឹកអណ្តូងម៉ងរួចពួកអ្នកស្រុកណុងថាខ្ញុំឆ្កួតស្រាតអត់មានខោអាវផ្លាស់អីទេណា។ អើបើមានស្អីបើអត់ការទៅហើយបើខោអាវមួយកំភ្លេចឹងហាសមុជទឹកមុជទឹកដល់ស្រទឹកទៅដឹងទៅនៅណាទៅអីនៅហ្នឹងស្រាតរួចស្លៀកមកវិញមករួចថាខ្ញុំឆ្កួត អើឆ្កួតទៅដុះពុកមាត់ស្រមេមស្រមួមធ្វើឡេកឡាក់ៗទៅសមទៅដល់អាណុងជំនាន់ណុងទាល់តែចឹងវាអាណិតយើងវិញ។

ក៖ បាទកុង!

ខ៖ ប៉ុនយើងអត់មានទៅប្រឆាំងតវ៉ាស្រែកអីនេះគេឱ្យប៉ុន្មានស៊ីប៉ុណ្ណឹងទេ គេមិនឱ្យស៊ីក៏ហីទៅចឹងទៅណាស់។

ក៖ ថ៎ស!

ខ៖ គេឱ្យធ្វើអីធ្វើណុងតាមគេណុងទៅទូលដូចថាធ្វើអីអាចម៍ដាក់ជីអីទូលអាចម៍រែកអាចម៍ហ្នឹងហាស តាមវាទៅណាស់យើងកុំទៅប្រឆាំងជាមួយវារស់ហើយ។

ក៖ បាទកុងបាទ!

ខ៖ ជួនកាលវាឃើញយើងអាណិតគេហៅចូលស្ងាត់ៗវាឱ្យបាយឱ្យបាយស៊ីមួយបានអីចឹងទៅ។

ក៖ អ៎ូបាទ!

ខ៖ ចឹងហាស!

ក៖ ថ៎ស!

ខ៖ ដល់ខ្ញុំគ្រុនចាញ់ គ្រុនចាញ់របៀបអាគ្រុនចាញ់ហ្នឹងដូចជាមិនមែនជាគ្រុនមូសខាំទំនងនេះគ្រុនទឹកគ្រុនដីចាញ់ទឹកចាញ់ដីទេ។

ក៖ ថ៎ស!

ខ៖ វាប្រាប់ថាចេះវាឱ្យខ្ញុំទៅនៅអីឱ្យនៅអណ្តូងលូក។

ក៖ បាទកុង!

ខ៖ អណ្តូងលូកហ្នឹងវាអាទឹកណុងដល់ពេលភ្លៀងមកអណ្តូងណុង តែមួយលូកដៃយើងទេដួសទឹកប្រើបានហើយ។

ក៖ ចុម..!

ខ៖ ពេលរាំងពេលចឹងទឹកសធម្មតាយើង។

ក៖ បាទកុង!

ខ៖ ដល់ភ្លៀងមកបិប។

ក៖ ហៀរ?

ខ៖ ហៀរមែន ប៉ុន្តែទឹកណុងពណិសដូចទឹកកំបោរចឹងហាស។

ក៖ អ៎ូ!

ខ៖ ដល់រាំងភ្លៀងយើងត្រូវការប្រើអីអ្នកណាប្រើលូកទឹកហ្នឹង។

ក៖ បាទកុង!

ខ៖ ទៅញ៉ាំអាហ្នឹងបែបចាញ់អាហ្នឹង។

ក៖ អ៎ូ!

ខ៖ ដល់ទៅវាអើស្រៀវស្រាញឈឺឆ្អឹងខ្នងទៅបានបាត់ដ ល់នេះទៅទៅជាម៉ោង៦អីញាក់ហើយ ញាក់ហើយយកដុំថ្មទឹកក្តៅអីមកឱបចឹងហាសណា៎។

ក៖ បាទកុង!

ខ៖ បាទ! ដល់ពេលអស់ក្តៅអស់ពីរងាខឹងត្រឡប់មកវិញទៅជាក្តៅ ក្តៅបានអាទឹកហ្នឹងធឹក។

ក៖ អ៎ូ!

ខ៖ រួចអាកណ្តុងទឹកហ្នឹងចូលទៅព្រៃតំបែណុងហាស។

ក៖ ច៎ាស!

ខ៖ ចូលព្រៃតំបែពួកអ្នកម្ចាស់វាអត់និយាយទេ ព្រោះវាយើងអ្នកនិយាយប្រវត្តិយើងប៉ុនចៃដន្យវានាំយើងទៅបេះអាស្លឹកខាតណាយើងយកមកដេរធ្វើដំបូលហោស។

ក៖ បាទកុង!

ខ៖ ដេរធ្វើដំបូលហោស រួចដល់ដាស់ទៅខ្ញុំចេះតែឆ្ងល់ចុមអាដើមវល្លិ៍មួយហ្នឹងថាខាតណារួចអ្នកស្រុកហ្នឹងអត់ទៅបេះរួចគេរាល់គ្នាចេះតែគេចៗរួចខ្ញុំឃើញចឹងទៅបេះ អាកន្តាច់ខាំជើងហោស។

ក៖ អ៉ូ!

ខ៖ គេចអាកន្តាច់ហ្នឹងទៅវិបកុំអីធ្លាក់ចូលរណ្តៅអាប៉េហាស រូចកុំបានតោងអាវល្ស៏ណុងជាប់ហាសរូចទៅបានដើរចេញមកវិញ ដើរចេញពីរណ្តៅអាប៉េទៅមុនបន្តិចរោងបាយរោងបាយអាយាគកុងហោស។

ក៖ បាទកុង!

ខ៖ រោងបាយអាយាគកុងនៅពេញព្រៃតំប៊ែហ្នឹងហាស។

ក៖ អ៉ូ!

ខ៖ រូចទៅដើរទៅបានរើសបានអាកន្តុងទឹកណុងមកដល់មកដាំទឹកផឹកឱបហិតតែកន្តុងទឹកណុងអានុស្សាវរីយ៍។

ក៖ អ៉ូ!

ខ៖ កន្តុងទាហ៊ានហាស!

ក៖ បាទកុងបាទ!

ខ៖ កន្តុងទាហ៊ានប៉ុនអាពូកណុងវាអត់ថាខ្ញុំទាហ៊ានទេ ព្រោះខ្ញុំប្រាប់វាថាសិស្សខ្ញុំយកអាកន្តុងទឹកណុងអើកន្តុងទឹកហ្នឹងយកពីព្រៃមកបោចអាខ័នម៉ាធ្វើដំបូលផ្ទះហ្នឹងមានអីពិបាកជំនាន់អាពតពិបាកចង់ងាប់ហើយ រឿងណុងហោស ឱនស្ទូងគ្រាន់ចុកចង្កេះងើបល្មមម៉ោង១២ម៉ោងមួយងើបមើលរកបាយមកទាន់មកដល់ទេណ៉ា ប៉ុនពូកថ្មីវាស៊ីបាយរូចអស់យកចាស់វាស៊ីបាយរូចហើយ។

ក៖ បាទកុងបាទ!

ខ៖ បានដឹករទេះឱ្យងងស៊ីម៉ោងពីរណុងល្មមស៊ីបាយហាស។

ក៖ អ៉ូ!

ខ៖ អើបើមែនស្វូងមែនស្វូងក្បែរភូមិណាស្វូងឆ្ងាយៗហោស។

ក៖ អើ!

ខ៖ ដល់ពេលធ្វើស្រែហើយបានហើយវាមែនអោយយើងដាំបាយស៊ីទេ។

ក៖ អត់ទេ?

ខ៖ វាយកឡានអាស៊ីលវាណុងមកពីណាទេណា៎។

ក៖ បាទកុង!

ខ៖ ចិតប្រាំមួយចិតប្រាំពីរហ្នឹង មកទយក្តិតលើកស្រូវយកទៅអស់ហើយដល់អ្នកស្រុកហ្នឹងអ្នកចាស់ហ្នឹងទំនងដល់យូរៗទៅមានគំនិតមួយដែរអញធ្វើការហាត់ចង់ងាប់អស់បានស៊ីវីនិយាយជាមួយខ្ញុំអ្នថ្មីចឹងហាស។

ក៖ ចា៎ស!

ខ៖ នាំគ្នាទៅធ្វើរោងខាងកើតព្រៃតំបែហ្នឹងហាស។

ក៖ បាទកុង!

ខ៖ ច្រូតស្រូវលាក់ទៅទុកយកមកដាំបាយញ៉ាំហាសដាំបបរដាំអីហោស។

ក៖ ចា៎ស!

ខ៖ អើបើចិតប្រាំចិតប្រាំមួយចឹង ចិតប្រាំពីរក៏ចឹងដល់យកទៅលាក់ដល់ទំនងអាពតចូលហោសចិតប្រាំពីរចូលហោស។

ក៖ បាទ!

ខ៖ វែនកអាអ្នកថ្មីហ្នឹងអើអាអ្នកចាស់ហ្នឹងយកស្រូវដាក់ក្នុងព្រៃ។

ក៖ អើ!

ខ៖ អើឱ្យទូលយកមកវិញអើយរួចអ្នកអាអ្នកចាស់ហ្នឹងហាស វាថាបាតុកម្មក៏ថាបានអើបើវាឆ្នាំចិតសិបប្រាំវាមិនធ្វើបាបយើង។

ក៖ អ៎ូ!

ខ៖ ចិតប្រាំមួយវាមិនធ្វើបាបយើង។

ក៖ ច៎ាស!

ខ៖ ដល់ចិតប្រាំពីរអាពួកហ្នឹងទៅដល់វាមានអាអ្នកថ្មីយើងវាមិនសូវធ្វើបាបទេ។

ក៖ បាទកុង!

ខ៖ វាមិនសូវធ្វើបាបទេ រួចខ្ញុំវិញអ្នកថ្មីអត់សូវធ្វើបាបទេចូលទៅសួរតែអាប្រធានភូមិអាមេកងមេហ្នឹងហាសអាខ្លះរត់ចូលព្រៃហាស។

ក៖ បាទកុង!

ខ៖ រត់ចូលព្រៃអាបុិមួយរត់ចូលព្រៃទៅវាលែងរករឿងអាណុងអាណុងទប់មិនបានយកប្រពន្ធយកកូនទៅវាយចោលបាត់ទាល់សព្វថ្ងៃហ្នឹងហាស។

ក៖ អ៎ូ!

ខ៖ រួចអាបុិហ្នឹងនៅរស់ទាល់សព្វថ្ងៃអាបុិហៀងហ្នឹងហាស។

ក៖ អ៎ូ!

ខ៖ ប៉ុន្តែថាឥឡូវហ្នឹងវង្វេងហើយឥឡូវហោស។

ក៖ ចាស់ហើយណោះកុង?

ខ៖ ចាស់ហើយ វង្វេងហើយថាស្លៀកខោស្លៀកអីអត់ជាប់ទេ កូនស្លៀកឱ្យមួយពោះមុនងាប់អស់ហើយ។

ក៖ អ៎ូ!

ខ៖ ឈ្មោះតាហឿនស្អីហឿនទេខ្ញុំហៅហឿនៗសមមិត្តហឿន។

ក៖ អូបាទ! ចុះអើកុងគិតថាជំនាន់ប៉ុលពតណុង គេឱ្យកុងធ្វើអីគេខ្លះទៅជំនាន់ណុង?

ខ៖ ជំនាន់ណុង?

ក៖ បាទកុង!

ខ៖ អើខ្ញុំមុនដំបូងទៅដកស្វូងដូចអ្នកស្រុកចឹងហាស វាយសំណាបវាយអីចឹងហាណាស់ រួចកាលណុងអើអាវអីយើងអាជំនាន់ចិតខ្ញុំខ្ញុំពាក់ធ្វើទាហ៊ានហោស។

ក៖ បាទកុង!

ខ៖ ដើរកាន់កាំភ្លើងធំនៅព្រៃករទាំងព្រៃកហ្វរយើងតាខ្មៅយើងនេះ។

ក៖ បាទកុងស្គាល់។

ខ៖ នៅព្រៃកហ្វរព្រៃកអាទាំងយើងហ្នឹងហាស។

ក៖ បាទ!

ខ៖ ព្រៃកហ្វរឆ្លងស្ពានព្រៃកហ្វរមិនមានកាំភ្លើងធំមួយហើយ។

ក៖ បាទ!

ខ៖ ដល់បត់ទៅផ្លូវជាតិលេខពីរព្រៃកអាទាំង។

ក៖ បាទ!

ខ៖ ហួសព្រៃកទាំងប្រហែលមួយគីឡូដីទៅដាក់កាំភ្លើងធំមួយហើយខ្ញុំនៅទីណុងហោស។

ក៖ បាទកុងបាទ!

ខ៖ បាទ! រួចបានខ្ញុំធ្វើទាហ៊ានចេះចិតពីរយើងវាយបែកកំពង់ចាមហ្នឹងហោស។

ក៖ បាទ!

ខ៖ វាយបែកកំពង់ចាមយើងហ្នឹង ខ្ញុំក៏រត់ទៅភ្នំពេញទៅរួចយើងអត់មានការងារធ្វើយើងដើរដើររកការងារធ្វើផងអីផង រួចអាងថាខ្លួនយើងរៀនខាងបច្ចេកទេសគេនៅបឹងកុកហ្នឹងរៀនសាលាបច្ចេកទេសគេមានបច្ចេកទេសហាសណា៎។

ក៖ បាទកុងបាទ!

ខ៖ បាទដល់រោងចក្រគេបិទគេអត់ទទួលរោងចក្រដើរដើរទៅគេចាប់យើងធ្វើទាហាន។

ក៖ អ៎ូ!

ខ៖ អើហៅកាតកិច្ចយោធាអើបរិច្ចាកយោធារួចដល់ចាប់ខ្ញុំធ្វើទាហានខ្ញុំថា អើខ្ញុំមានសញ្ញាប័ត្រចេះៗដែរហើយខ្ញុំទើបមកដល់ភ្នំពេញទេចិតពីរហ្នឹងខ្ញុំនៅកំពង់ចាមពួកខ្មែរក្រហមវាយបែកកំពង់ចាម។ ខ្ញុំរត់មកភ្នំពេញហ្នឹងទេ អើរួចគេចាប់ខ្ញុំធ្វើទាហានដល់នេះទៅខ្ញុំថាបើនេះតាមនោះវាយកយើងទៅហាត់នៅកំបូលសេអ៊ីកូនទាហានទេណា៎។

ក៖ បាទកុង!

ខ៖ កូនទាហានទេចឹងខ្ញុំប្រាប់មានតែសក្តិប្រាំហ្នឹងហោស។

ក៖ បាទ!

ខ៖ វាយអាពួកហ្នឹងទៅប្រាប់ពួកហ្នឹងទៅឱ្យទាក់ទងជួយទាក់ទងចាក់សំបុត្រទៅតា តាគាត់លែងវាមកវិញមកអើរួចដល់ទទួលលែងខ្ញុំទៅទទួលគេរើសទាហានមេទាហាននៅកំពង់ឆ្នាំងសាលាចាន់សារិហាស។

ក៖ បាទកុង!

ខ៖ អើសាលាហាត់ទាហាននៅកំពង់ឆ្នាំងតាខ្ញុំពិបាកពេករកការងារធ្វើមិនបានទេ ខ្ញុំទៅហាត់កំពង់ឆ្នាំងហើយអាណុងធ្វើជាមេគេផងអើទៅទៅ។

ក៖ បាទ!

ខ៖ តាក៏ឱ្យទៅៗ។

កៈ អ៉ូ!

ខៈ ជិះយន្តហោះទៅហាត់កំពង់ឆ្នាំងទៅចិតពីរហាសចិតបីហាស។

កៈ បាទកុង!

ខៈ ហាត់កំពង់ឆ្នាំងចិតបីចិតបីហាត់បានមួយឆ្នាំដល់ចូលចិតបួនគេឱ្យមកកាន់កាំភ្លើងធំនៅព្រៃអាទាំងហ្នឹង។

កៈ អ៉ូ!

ខៈ រួចកាន់កាំភ្លើងធំហ្នឹង បើសិនណាគ្មានខ្សែប្រហែលទំនងអត់បានទៀត។

កៈ ច៉ាស!

ខៈ ប្រហែលជាអាំងហ្វង់ទីខ្សែត្រៀមមុខហើយ។

កៈ បាទកុង!

ខៈ បានតាហ្នឹងហាសហើយទំនងគាត់មិនថារឿងគាត់មិនឱ្យចៅបានចិត្តអារឿងបក្សពួកហ្នឹងហាស។

កៈ បាទកុងបាទ!

ខៈ គាត់ប្រាប់ទៅតាណុងឥដ្ឋសួង ជំនាន់ណុងឥដ្ឋសួងខាងពលកងពលធំលេខមួយ។

កៈបាទកុងបាទ!

ខៈ អើកងពលធំលេខមួយប្រាប់ទៅប្រហែលទំនងប្រាប់គាត់ ព្រោះបានប្រាប់គាត់ឱ្យដឹងបានខ្ញុំមើលដឹងគាត់ញឹមញៀមៗឃើញឈ្មោះខ្ញុំបានគាត់ញឹមញៀមៗ គាត់សរសេរហៅខ្ញុំ ហៅទៅយើងស្រួលលុយហាសណា៎ពេលសង់តេប្រាប់គាត់ចឹងទៅចឹងគាត់មើលមុខមើលរាងរូវញឹមញៀមៗសរសេរក្រដាសមួយឱ្យទៅខាងកាំភ្លើងធំទៅ រួចពួកណុងសួរអើហែងទៅណាដល់វានេះអូទៅកាំភ្លើងធំរួចហែងម៉េខស្គាល់គេ គេឱ្យទៅខាងណុងទៅទៅ។

ក៖ អ៉ូ!

ខ៖ ទៅទៅរួចទៅនៅខាងណុងគេទៅហើយមុនហ្នឹងទៅណុងហាសចេះបានបានថារើសប៉ុស្ត៍អងដេអ៊ីកាលណុង ខ្ញុំរៀនហោសក៏សិស្សប្រហែលមួយរយនាក់ជាងហាសមួយជំនាន់ខ្ញុំហ្នឹងហាស។

ក៖ បាទៗកុង!

ខ៖ អើនេះប្រមូលខ្ញុំណុងឈ្មោះអើអីទេនេះតារ៉ាអ៉ូបូរ៉ាឈ្មោះបូរ៉ាអាបូរ៉ាណុងហើយជំនាន់ខ្ញុំហៅជំនាន់អ៊ឹងប៉ោហោង។

ក៖ បាទកុង!

ខ៖ អើលោកមេទាហ៊ានអ៊ឹងប៉ោងហោងហ្នឹងគាត់ធ្លាក់យន្តហោះនៅខាងនេះនៅខាងឧត្តុងនេះ។

ក៖ បាទ!

ខ៖ គាត់ស្លាប់ទៅដល់នេះជំនាន់ណុងទាល់សាមសិបមួយទីសាមសិបមួយមេទាហ៊ានទីសាមសិបមួយ អារួចទៅទៅដល់មើលទៅនៅអាកន្លែងគេចាត់តាំងទាហ៊ានហោសយើងមិនយើងធ្វើដូចគ្រូចឹងហាស។

ក៖ បាទកុងបាទ!

ខ៖ គេទៅយើងមិនចាប់ប៉ុស្ត៍។

ក៖ បាទ!

ខ៖ ចាប់ប៉ុស្ត៍អាណុងទាហ៊ានណុងគេអ្នកណាៗគេលេខមួយលេខពីរអីចឹងទៅគេទៅរើសគេស្រឡាញ់ប៉ុស្ត៍ណាស្រឡាញ់ទៅណាៗគេទៅខ្លួនគេហាសណា។

ក៖ បាទកុង!

ខ៖ ដល់ងារចុងក្រោយធ្លាក់ខ្ញុំបុកពោះខ្ញុំថាអញប្រហែលទៅពួកអាកងទាហ៊ានអាពួកកំាវាយ ហាសអាជើងវាយហាសណា អាត្រីប៉េអ៊ីអាអងដេអ៊ីសុទ្ធតែពួកវាយហាសណាំ។

ក៖ បាទកុង!

ខ៖ អើពួកឌឺដេអ៊ីពួកសុទ្ធតែពួកវ៉ៃហើយនៅសល់រួចខ្ញុំអង្គុយស្ងៀមទទួលស្គាល់ចេះ។ កាលខ្ញុំនៅក្មេងចឹងប៉ុនៗណុងហាសផ្ទះខ្ញុំយាយខ្ញុំហ្នឹងគាត់ផ្ទះធំរួចគាត់ជួលឱ្យកូនសិស្សនៅហាសជំនាន់សម្តេចឪហោសមិនទាន់សង្គ្រាមហោស។

ក៖ បាទកុង!

ខ៖ ជួលទៅគាត់រៀននៅណុង ហើយខ្ញុំឧស្សាហ៍ឃើញគាត់អីចឹងហាសណាំដល់ជំនាន់សង្គ្រាមហ្នឹងជំនាន់លន់នល់ហ្នឹងឃើញ គាត់ប៉ុនមិនដឹងគាត់ឈ្មោះអីទេដល់ឃើញគាត់ជម្រាបសួរខ្ញុំឃើញជម្រាបសួរ ស្អីហាសទាហានហែង ជម្រាបសួរបានតុយណុយ គាត់សួរហែងនៅណាហែងស្គាល់អញថាខ្ញុំធ្លាប់ឃើញពូនៅកាលពូនៅរៀននៅជួលផ្ទះយាយនៅភូមិមេម៉ាយអីចឹងហាសណាំ ថាអ៎ូហែងអាមួយនេះហ្នឹងហេសចឹងហាសថាចឹងទៅគាត់ថាហែងរួចនៅណាឥឡូវ អើខ្ញុំនៅសន្តិសុខប៉ុស្តិ៍ពីរបីហ្នឹងសុទ្ធតែទាហ៊ានអើរួចហែងខ្លាចងាប់ធ្វើទាហ៊ានខ្ញុំញឹមញែមៗទៅគាត់ថាឥឡូវហែងយករកយាយៗសួរយាយខ្ញុំសួរម្តាយខ្ញុំនៅណាអីណាថាម៉ាក់ប៉ាយាយអីមកភ្នំពេញអស់ហើយទៅយកអងឌីទៅទាហ៊ានវាយអើខ្លាចអីហែងធ្វើទាហ៊ានវាយរួចចឹងរួចគាត់ញឹមញែមៗក៏ហីទៅ គាត់នៅតែខ្ញុំទៅណាទៅយកណាផ្សេងមិនដូចថាមកកំពង់ចាមវិញមកណាវិញវាឆ្ងាយពីម៉ែឪវិញហើយណាំ។

ក៖ បាទៗកុង!

ខ៖ ចឹងយកអានោះទៅយកអងដេអ៊ីហ្នឹង នៅក្បែរណុងក្បែរតាខ្មៅណុងទៅដល់រួចអាតាសឺរធំនៅត្រង់អានេះណុងអាស្តុបបូកគោហោស។

ក៖ បាទកុង!

ខ៖ ពីដើមកាចជ្រុងណុង។

ក៖ ស្គាល់!

ខ៖ អើអងដេអ៊ីណុងហាស។

ក៖ អ៎ូ!

ខ៖ បាទ!

ក៖ កន្លែងការ៉ាសសាំងហ្នឹងហោសកុង?

ខ៖ បាទ!

ក៖ កន្លែងការ៉ាសសាំងហ្នឹងហោស?

ខ៖ បាទការ៉ាសសាំងហ្នឹង កាលមុនធ្វើអាអងដេអ៊ីហ្នឹងពូននៅកន្លែងហ្នឹង។

ក៖ អ៎ូ!

ខ៖ កងពលធំលេខមួយនៅណុងហាស។

ក៖ បាទកុង!

ខ៖ បាទ!រួចទៅអើដល់នេះទៅទៅបង្ហាញគេនៅអងដេអ៊ីណុង កងដេអ៊ីណុងគាត់ថាឥដ្ឋសួងគាត់ធ្លាប់ស្គាល់ធ្លាប់ឃើញកាលណុងតាខ្ញុំមូទៅគ្នាគាត់ខ្ញុំសុំៗហោសគាត់ប៉ុនដូចយើងចេកចាច ដូចយើងណាតែបានមករួចទៅសួរហាស ដូចថាយើងទៅឈរជើងកន្លែងណុងហាសទៅកន្លះខែទៅចឹងមេខ្ញុំសក្តិពីរសក្តិបីហ្នឹងហាសគាត់មកលេងផ្ទះម្តងរួចខ្ញុំនៅណុងទៅពីមួយអាទិត្យពីរអាទិត្យអីចឹងហាសណា៎។

ក៖ បាទកុង!

ខ៖ គាត់មកម្តងរួចគាត់ឱ្យមកផ្ទះវិញមកផ្ទះលេងមករួចប្រាក់ខែមានចាយណាមានតែឱ្យម៉ែហើយអង្ករបានមួយប៊េឱ្យម៉ែវាម៉្យាងដែរ ព្រោះបើយើងធ្វើការកំប៊េកកំប៉ុករស់ពិបាកហាសណា៎មិនងាយធ្វើអត់អង្ករទេ ជំនាន់ណុងហាសជំនាន់លន់ណន់ហាស។

ក៖ បាទកុង!

ខ៖ ខ្លះគេដាច់អង្ករហាស ដាច់អង្ករហាសបានចឹងទៅទៅកាងចឹងទាក់ទងជាមួយកូនទាហ៊ានអាខ្លះវាទៅកាចអាដើមសង្កៀហោស។

ក៖ បាទកុង!

ខ៖ នៅតាមជាយផ្លូវណុងហាស។

ក៖ បាទ!

ខ៖ ចូលព្រៃតិចៗកាប់ដើមសង្កៀណុងជាកង់ៗចងបាចខ្ញុំថាហែងមិនបាចយកទៅលក់អីណាទេ លក់ឱ្យអញមកអញឱ្យលុយដឹកឱ្យនៅផ្សារដើមគរហ្នឹង នៅផ្សារដើមគរលក់ហោសទៅផ្សារដើមគរទៅបានចំណេញបានអីចឹងទៅអាណុងនៅកម្លោះទេ។ កាលធ្វើទាហ៊ានណុងនៅកម្លោះទេ។

ក៖ បាទ!

ខ៖ មិនទាន់ធ្វើអីទេ ដល់ចិតអើដល់ចិតប្រាំពីរចិតប្រាំបីបានការប្រពន្ធ។

ក៖ អ៎!

ខ៖ អើបើនិយាយរឿងប្រវត្តិនៅពីតូចរៀន រៀនហាសដូចថាកម្សត់ដែរ ឪពុកខ្ញុំធ្វើជាងមាសហើយម្តាយខ្ញុំអ្នករកស៊ីរួចតាខ្ញុំហ្នឹងតាប៉ាត់ហ្នឹងអើយាយបាចហ្នឹងតាពិតយាយតាហ្នឹងមែនជីដូនជីតាបង្កើតទេណា។

ក៖ បាទ!

ខ៖ កូនចិញ្ចឹមម្តាយខ្ញុំទេ ម្តាយខ្ញុំត្រូវជាក្មួយយាយខ្ញុំហ្នឹងហាស។

ក៖ បាទកុង!

ខ៖ យកមកចិញ្ចឹមរួចទៅដល់ទៅរៀនទៅអីចឹងទៅអើប៉ុនៗហ្នឹងរួចសាលានៅត្រង់ម្តុំភូមិមេម៉ាយហ្នឹងមករៀននៅសាលាឧត្តរ។

ក៖ បាទកុង!

ខ៖ រួចតាតាប៉ាត់ណុង គាត់ស្គាល់គេខ្ញុំនៅតូចហ្នឹងអត់ឱ្យរៀនថ្នាក់ទីមួយទេ ព្រោះខ្ញុំរៀនសាលាឈ្នួលហ្នឹងមករៀនថ្នាក់ទី២ កាលណុងរាប់ពីមួយពីរមកវិញហាស។

ក៖ បាទកុង!

ខ៖ រួចកាលមុនម៉ាមុនខ្ញុំមួយឆ្នាំពីរហ្នឹងគេហៅកុមារដ្ឋាន។

ក៖ បាទ!

ខ៖ បារិកុមារដ្ឋានបារិ អាទិចឹងហាស!

ក៖ បាទ!

ខ៖ មែនហៅថ្នាក់ទីមួយទីពីរទេ ដល់ក្រោយមកទៀតបានដូរឱ្យដាក់ថ្នាក់ទីមួយទីពីរ។

ក៖ បាទកុង!

ខ៖ រួចដល់រៀនចឹងទៅគេវាលធ្វើបាប។

ក៖ អ៎ូ!

ខ៖ ទំនងមានក្រុមគេរឹក៏បងប្អូនកូនចៅគេណាអ្នកនេះកាន់កាតាបទៅរៀនចឹងហាស!

ក៖ បាទកុងបាទ!

ខ៖ អើទៅរៀនចឹងទៅជួនកាលវាទៈកាតាបឯងឱ្យធ្លាក់បែកកាតាបទៅអាក្តារខៀនពីដើមមែនក្តារខៀនក្រដាសអាដែកណាថ្ម។

ក៖ បាទកុង!

ខ៖ បែកមកដល់ផ្ទះម៉ែវាយថាគេធ្វើខ្ញុំទេ មែនទម្លាក់ទេចឹងទៅអើរួចទៅប៊ីចដាក់ហោប៉ាវអាវអីចឹងខ្លាចគេយកថាដាក់កាតាបដាក់ក្នុងថតតុខ្លាចគេយកដាក់ហោប៉ាវអាវអាធំៗមកលបប្រឡំយកបាត់ អើដីសអីដាក់ហោប៉ាវអាវយកបាត់ដល់រៀនគ្រូហៅសរសេរតាមអានទាមក្តារខៀនទៅអត់ដីសសុំគេគេមិនឱ្យ។

ក៖ អើ!

ខ៖ យូរៗទៅដូចជានេះដូចជាមុាំងជាំៗដូចនៅពីក្មេងហាស។

ក៖ ច៎ាស!

ខ៖ រួចដល់រៀងធំតិចហើយនេះធំប៉ុនណោះ ហើយចូលកាឡះចូលអីហើយណ៎ា។

ក៖ ច៎ាស!

ខ៖ គេមិនហៅខ្ញុំអើខ្មាយសិរី ឬអាសិរីទេ គេហៅខ្ញុំអាខ្មាយ អស់ពីអាខ្មាយទៅយូរៗទៅគេហៅអាខ្មែរសិរីអើរួចជំនាន់សម្តេចសីហនុហោស។

ក៖ បាទកុង!

ខ៖ ហៅឯងអាខ្មែរសិរីចុមអញខ្មែរសិរី ឪម៉ែអញខ្មែរសិរីបានគេហៅអញខ្មែរសិរីភ័យហោសរួចជំនាន់ណុងជំនាន់សម្តេចសីហនុមិនព្រាបឥនទៅបាញ់ចោលអីនោះ។

ក៖ បាទកុង!

ខ៖ អើភ័យរួចពួកអាអ្នកស្រុកម្តុំភូមិមេម៉ាយហ្នឹងពីដើមអាខ្លះគ្មានស្គាល់ហៅខ្ញុំអាខ្មែរសិរីជួនកាលអើពេលណុងដើរមកផ្ទះរៀននៅក្មេងតូចៗហោស!

ក៖ បាទកុង!

ខ៖ ជួនកាលខ្ញុំចូលផ្ទះជេរអាខ្មែរសិរីអាក្បត់ជាតិកូនអាក្បត់ជាតិចុមម៉េចចេះ ចេះតែភ័យហោស ប៉ុនចេះតែភ័យៗរួចម៉ែខ្ញុំប្រាប់ថាកូនអើយកុំមាត់គេថាអីថាទៅ។

ក៖ គ្រាន់តែឈ្មោះយើងទេណោះកុង?

ខ៖ បាទៗ! រួចគេគាត់ថាមួយមាត់ទៅខ្ញុំនៅចាំទាល់សព្វថ្ងៃគាត់ថាកូនអើយគេជេរយើងយើងដេកលក់ បើកូនឯងជេរគេយើងដេកអត់លក់ទេចឹងហោស?

ក៖ បាទកុង!

ខ៖ បាទ! ខ្ញុំចាំពាក្យទាល់សព្វថ្ងៃចឹងទៅ។

ក៖ ប៉ុន្តែកាលកុងរៀនហ្នឹងនៅជំនាន់ណាអ៊ីសារ៉ាក់មែនកុង?

ខ៖ អត់ទេជំនាន់សម្តេចសីហនុហាស។

ក៖ សម្តេចសីហនុហោស?

ខ៖ ហ្នឹងហើយ រួចដល់ខ្ញុំរៀនហ្នឹងដល់ចូលលីសេហ្នឹង ប្រឡងធ្លាក់ទេអត់ជាប់ទេចឹងជីដូនខ្ញុំឱ្យទៅរៀនសាលាឈ្នួលហាជនហោស។

ក៖ បាទកុង!

ខ៖ អាណុងពេញចឹងហើយគ្មានអាសិរីអីទេ អាខ្មាយសិរីអាខ្មែរសិរី រួចខ្ញុំកាលណុងគេកំពុងតែផ្ទើលហោសរឿងចាប់ខ្មែរសិរីរកបាញ់ចោលព្រាបឥនព្រាបអីណុងហោស។

ក៖ បាទកុង!

ខ៖ បាញ់ព្រាបឥនណុងមួយទៅ ក្រោយមកទៀតបាញ់សៅប៊ូរី ខេតអឿន សងុយស្ទឹៗណុងហោសប្រាំប្រាំមួយនាក់ទៀតហោសរិទ្ធិតែភ័យទៀតហើយ។

ក៖ ឈប់រៀន

ខ៖ អើអត់ឈប់រៀនទេ យើងចេះតែភ័យរឿងគេខ្លាចគេធ្វើបាបយើងហោស។

ក៖ បាទកុង!

ខ៖ យើងចេះតែភ័យចេះតែរៀនៗទៅដល់ចិតអើប្រាំបីខ្ញុំប្រឡងលីសេធ្លាក់ណោះទៅប្រឡងសួងប្រឡងជាមួយ យកគេថាពួកហ្នឹងរៀន រៀនទៅមួយរៀនហ្នឹងវាប្រឡងធ្លាក់។

ក៖ បាទកុង!

ខ៖ ចឹងដល់ចូលកងគេឱ្យវាប្រឡងម្តងទៀតកូនសិស្សហ្នឹងហាស។

ក៖ បាទ!

ខ៖ យើងដាក់ឌីម៉ងប្រឡងជាមួយអាពួកធ្លាក់ហ្នឹងហាស។

ក៖ បាទ!

ខ៖ បានរៀននៅសួង។

ក៖ ចឹង!

ខ៖ ហុកប្រាំបីខ្ញុំរៀននៅសួងហុកប្រាំបី គេវាយគ្នាខ្លាំងហើយពួកវាយអាយៀកកុងហោសក្រោយកើតហោស។

ក៖ ក្រោយលន់នល់ហ្នឹងហោសកុង?

ខ៖ ហ៎! មិនទាន់វាយទេ ប៉ុនអាពួកព្រៃហ្នឹងហាស។

ក៖ បាទៗ!

ខ៖ ពួកអាមេរិចកាំងទម្លាក់គ្រាប់បែកកាំភ្លើងស្លៀក្រហមទម្លាក់មកឆិលរន្ទៀលពេឡមេយហើយ!

ក៖ បាទៗ!

ខ៖ ផ្កាយដុសកន្ទុយស្គាល់ផ្កាយដុសកន្ទុយខ្ញុំស្គាល់តាំងពីណុងមក។

ក៖ ស្គាល់!

ខ៖ ម៉ោងប្រាំហែលប្រាំល្ងាចអើម៉ោងប្រាំយប់។

ក៖ ប្រាំព្រឹកហីកុង?

ខ៖ ប្រាំព្រឹកហីបួនកន្លះហ្នឹងណាស់។

ក៖ បាទ!

ខ៖ អាដូចផ្តុំមូលប៉ុណ្ណឹងហោស រួចឮសូរវេវាងាផ្តាយដុសកន្ទុយហាស។

ក៖ បាទៗ!

ខ៖ អាហ្នឹងអាសវែងហ្នឹងហាសស្គាល់តាំងពីណុងមកថាអ៉ូអ្នកស្រុកទៅហើយផ្តាយដុសកន្ទុយស្រុកកើតសង្គ្រាមហើយ ខ្ញុំក៏ថាមែនវ៉ែគ្នាក្តឹង។

ក៖ អ៉ូ!

ខ៖ ដល់ឆ្នាំចិតសិបខ្ញុំមករួចដល់ពេលហ្នឹងខ្ញុំហុកប្រាំបួន ខ្ញុំសុំផ្លាស់គេមករៀនវិទ្យាល័យព្រះសីហនុនេះ។

ក៖ បាទកុង!

ខ៖ រៀនមួយឆ្នាំមួយឆ្នាំហ្នឹងដល់ចិតសិបហុកប្រាំបួនចិតសិបដល់ចិតសិបបាតុកម្មហើយ។

ក៖ បាទកុង!

ខ៖ បាតុកម្មពួកអ្នកស្រុកនេះខាងក្នុងនេះភាគច្រើនខាងណេះខាងហាន់ជ័យនេះមកស្រែកអ៉ូជ័យោអាណាមិនទៅកាប់ចោលអីណាចឹងហាស។

ក៖ បាទកុង!

ខ៖ នៅកំពង់ចាមយើងហ្នឹងដល់នេះខ្ញុំអើកម្លោះហើយហាសណ៎ា។

ក៖ បាទកុងបាទ!

ខ៖ ខ្ញុំដប់ប្រាំពីរដប់ប្រាំបីហើយរួចទៅជាមួយយាយខ្ញុំចៅអើយកុំទៅមើលអីគេខ្លាចជាន់ដានគេអីចឹងហាសណា៎។

ក៖ បាទកុង!

ខ៖ ខ្លាចកុំទៅប៉ុនខ្ញុំចេះតែលួចអំពីអំពាលួចទៅម៉ែដល់ខ្ញុំនឹកឃើញ ឥឡូវអាណិតគាត់ជឿគេជំនឿអើបងស្រីទំនងប្រហែលបងខ្ញុំហាស ខ្ជង់សាមហើយសកលៀកសារ៉ុងយប់លើកបត់ជាពីរមកត្រឹមក្បាលជង្គង់ក្រវ៉ាត់ក្រម៉ារួចកាន់ផ្តាក់ទូលអ៊ូស្រែកអើយជំយោអាណាមិនទៅកាប់ចោល អាតាកុងឡានវាដឹងវាដាក់ឡានចឹងរត់ចូលក្នុងផ្សារហ្នឹងហាស។

ក៖ បាទកុង!

ខ៖ រួចទៅដល់ពេលអាពួកហ្នឹងវាឱ្យទារគាត់ណុងឱ្យមកបើកឡានដើរកម៉ងពេញមកមកបើកនឹក ប៉ុន្តែពួកហ្នឹងទៅទៅដល់ត្រឹមអាស្ពានជ្រោយចង្វារហោស។

ក៖ បាទកុងបាទ!

ខ៖ គេបាញ់ធ្លាក់ងាប់ខ្លះ។

ក៖ អ៊ូ!

ខ៖ រស់ខ្លះរត់មកវិញហើយ។

ក៖ បាទកុងបាទ!

ខ៖ បានរត់មកវិញអាខ្លះរត់តាមផ្នះខ្ញុំណុងគិតទៅសឭៗទៅមិនដឹងជា..។

ក៖ ហើយចុះកុងគិតថាអើជំនាន់លន់នល់ហ្នឹង យើងអត់មានបញ្ហាអីទេណោះកុងណោះ?

ខ៖ អត់ទេ។

ក៖ កុងនៅតែរៀនធម្មតា?

ខ៖ រៀនរៀនរួចទៅដល់គេវាយកំពង់ចាមបែកមានតែទៅភ្នំពេញទៅភ្នំពេញធ្វើទាហ៊ានភ្នំពេញ។

ក៖ អ៎ចុះគ្រាប់ផ្លោងហោសកុង?

ខ៖ ហាស?

ក៖ គ្រាប់ផ្លោងហោស?

ខ៖ អ៎គ្រាប់ផ្លោងឆ្នាំចិតសិប ខ្ញុំរៀននៅកំពង់ចាមទៅរៀនសាលាតិចនិចហ្នឹងហាស។

ក៖ បាទកុង!

ខ៖ គ្រាប់ផ្លោងណុងផ្លោងចង់លីសេយើងហាស។

ក៖ អ៎!

ខ៖ លីសេហ្នឹងងាប់កូនសិស្សម្នាក់ពីរទៅណា៎។

ក៖ បាទកុង!

ខ៖ ប៉ុនខ្ញុំរៀននៅសាលាតិចនិចនេះទេ។

ក៖ បាទ!

ខ៖ ប៉ុនគាត់ងាប់កូនសិស្សនៅសាលាលីសេទេ រឿងអីបានងាប់ចេះគ្រាប់ផ្លោងណុងហាសអាសាលាមើលអានេះអាទទឹងថ្ងៃហោសអាប៊ូដឹងប៉េអើអាប៊ូដឹងអាអាក្រោយហាសអាជូរក្រោយហាសណា៎។

ក៖ បាទកុង!

ខ៖ គ្រាប់ផ្លោងណុងប្រហែលផ្លោងមកពីជីរោទ៍ហោសផ្លោងប៉ឹងធ្លាក់សកលទេ ពីដំបូងហោស។

ក៖ បាទ!

ខ៖ រួចនាំគ្នាអើតមើលអាណាៗនោះធ្លាក់ទីនោះដល់មួយគ្រាប់ទៀតធ្លាក់មកចំអាក្រោយអាគារហ្នឹងហាសកន្លែងសួងដាំបន្លែដើមស្ពៃដើមខាតណាហ្នឹងហាស។

ក៖ បាទកុង!

ខ៖ ចឹងទៅវាអើតកត្រូវស្រីម្នាក់។

ក៖ ងាប់ទៅ?

ខ៖ ងាប់ទៅរួចទៅជូនកាលគ្នាអូសកង់ចេញពីរៀនម៉ោងប្រហែលជាម៉ោងបីកន្លះផ្លោងមកធ្លាក់ត្រូវ..។

ក៖ ហើយម៉េចទៀតទៅកុងចឹង?

ខ៖ អើឆ្នាំចិតសិបពីរហ្នឹងដែរ វាយកំពង់ចាមហ្នឹងមកចំប្អូនស្រីខ្ញុំមួយបានចឹងរណ្តៅជីកពីក្រោមផ្ទះហ្នឹងហាសនៅផ្លោងមកនៅអើស្វាងគ្រាប់ប្អូនស្រីខ្ញុំហ្នឹងអើវាជំទង់ហើយក្រោកដាំបាយឱ្យប្អូនស៊ី។

ក៖ បាទកុង!

ខ៖ ដល់ហើយផ្លោងមកចំក្រោកផ្ទះហ្នឹងក្រោយផ្ទះហ្នឹងត្រូវកំភ្លៅដាមសព្វថ្ងៃហ្នឹង។

ក៖ អ៎ូ!

ខ៖ ប៉ុនវាបានទៅនៅអាមេរិចហើយ។

ក៖ អ៎ូចឹងហោសកុង?

ខ៖ បាទ! ត្រូវកំភ្លៅនេះប៉ុនវាទៅនៅអាមេរិចហើយទៅនៅអាមេរិចអានេះ។

ក៖ អ៎ូ!

ខ៖ កូនមើលទី៣ទី៤។

ក៖ បាទកុង!

ខ៖ បងប្អូនខ្ញុំ៩នាក់នៅទាំងអស់ ខ្ញុំមួយប្អូនប្រុសខ្ញុំមួយធ្លរដែរ នៅកំពង់ចាមដែរនៅវាលវង់អើ ទូលស្បូវ មកប្អូនប្រុសអើមកបានប្អូនស្រីខ្ញុំនៅភ្នំពេញហោសបានមកបានអានេះហ្នឹងនៅអាមេរិចហ្នឹង អាទីប្រាំនៅសួងប្រុសទី៦ស្រីមានប្តីធ្វើការនៅធនាគាររួចទៅ៧សុទ្ធនៅទាំងអស់អាពៅអាពៅនៅអាមេរិចនៅក្រៅពីរនាក់។

ក៖ បងប្អូនកុងទាំងអស់ប៉ុន្មាននាក់ទៅ?

ខ៖ ប្រាំបួនប្រាំបួននាក់។

ក៖ ប៉ុន្តែនៅរស់ទាំងអស់ហោស?

ខ៖ នៅរស់ទាំងអស់។

ក៖ អ៎! កុងកូនទីប៉ុន្មានទៅ?

ខ៖ ខ្ញុំកូនទី១។

ក៖ អ៎បងគេហោស?

ខ៖ បងគេខ្ញុំទី១។

ក៖ ប៉ុន្តែប្អូនៗមានទៅអាមេរិចពីរនាក់កុងហោស?

ខ៖ បាទ!

ក៖ ទៅណុងទៅជំនាន់ណាជំនាន់អាវាយដាច់ហ្នឹងហោសកុង?

ខ៖ អត់ទេ! អានេះទៅមើលអើចិតប្រាំបួនប៉ែត្រសិបហើយបានវាទៅ។

ក៖ បាទកុង!

ខ៖ បើអាមួយនេះទៅមួយពាន់ប្រាំបួនរយបោះឆ្នោតហើយ។

ក៖ បាទកុង!

ខ៖ បោះឆ្នោតទី១ហើយណា៎។

ក៖ បាទកុងបាទ!

ខ៖ កៅប្រាំអីហើយទៅហោស!

ក៖ អ៎ូ! ប៉ុន្តែម៉េចបានកុងអត់ទៅដែរពេលណុង?

ខ៖ ខ្ញុំអត់ទៅវាយើងវាមានលទ្ធភាពអីហ្នឹងទៅវាប្អូនស្រីខ្ញុំទៅហ្នឹងវាមានចេះអើ វាមានបងប្អូនកាលជំនាន់ចិតប្រាំហ្នឹងជំនាន់លន់នល់ហ្នឹង។

ក៖ បាទកុង!

ខ៖ បងថ្លៃវាមើលបងចនបងអីទេ ប្តីវាបងថ្លៃវាហ្នឹងគាត់ត្រូវជាហើយអ្នកប្រចាំការទូតនៅញ៉ូយក។

ក៖ បាទកុង!

ខ៖ អង្គការស៊ីអង្គការសហប្រជាជាតិហាស។

ក៖ បាទកុង!

ខ៖ តាណុងដល់ចិតសិបប្រាំទៅគាត់ជាប់នៅណុងទៅដល់ចិតប្រាំបួននេះគាត់ចាក់សំបុត្រមករកបងប្អូនគាត់ហាស។

ក៖ បាទកុងបាទ!

ខ៖ បាទរួចទៅបានដោយប្អូនស្រីខ្ញុំមួយដៃរថាត្រូវរបួសជើងហ្នឹងដៃរយកអើប្អូនស្រីខ្ញុំហ្នឹងយកអើប្អូនគាត់។

ក៖ អ៎ូបាទកុង!

ខ៖ ប្អូនគាត់អើបានចេញទៅ។

ក៖ ក៏បានទៅទៅ?

ខ៖ បាទរួចខ្ញុំនៅណោះយើងមានស្អីគេ។

ក៖ ប៉ុន្តែគាត់ទៅប៉ុន្មានជាងសែសិបឆ្នាំហើយណោះកុងណោះ?

ខ៖ បាទ!

ក៖ គាត់..?

ខ៖ ប៉ុនឥឡូវវាមកនៅភ្នំពេញឡើងចុះៗប៉ុនមកទៅលើកហ្នឹងវាទៅវិញថាជាប់អាកូវីដហ្នឹងម៉េចអត់បានមក។

ក៖ ប៉ុន្តែគាត់អត់ធានាកូនចៅទៅទេណោះកុងណោះ?

ខ៖ វាពិបាកដែរ។

ក៖ គាត់..?

ខ៖ វាបានត្រឹមវាអត់បានអីវាដូចថាវាពិបាកដែរហាស។

ក៖ ជីវភាពគាត់នៅណុង..?

ខ៖ បាទ!

ក៖ យ៉ាប់ដែរហោសកុង?

ខ៖ បាទយ៉ាប់ដែរវាមែននេះណាបានដូចថាវាបានទៅហ្នឹងដោយសារបងថ្លៃទេណ៎ាដោយសារបងថ្លៃគាត់ធានាទៅទេណ៎ា។

ក៖ ចឹងគាត់ទៅជួយធ្វើការគេនៅណុងទៅ?

ខ៖ ជួយធ្វើការគេនៅណុងទៅ។

ក៖ អ៎ូ!

ខ៖ អាប្អូនពៅខ្ញុំនេះវាមានខាងប្រពន្ធធ្វើការនៅអាមេរិចណុងវាធ្វើពេទ្យកុមារពីមុនធ្វើពេទ្យកុមារនៅសៀមរាបនេះ។

ក៖ បាទកុងបាទ!

ខ៖ រួចទៅវាទាក់ទងជាមួយបងថ្លៃគេនៅអាមេរិចណុងហាស។

ក៖ អ៎ូ!

ខ៖ រួចបានបានគេសារសងគ្នាទៅអានោះគេរកទិញដីទិញអីសៀមរាបណុងត្រូវប៉ាន់គេលក់ទៅវាទៅទៅ។

ក៖ អ៎ូ!

ខ៖ រួចខ្ញុំនេះប៉ែត្របីហ្នឹងបានមកដីត្រង់កំពង់ចាមហ្នឹង។

ក៖ បាទកុង!

ខ៖ ចេះតែនៅៗទៅណា៎។

ក៖ បាទ!

ខ៖ អើទាល់បាននៅទៅប្រពន្ធខ្ញុំអីហ្នឹងធ្វើការណុងនៅណុងទៅដល់នេះដល់ចូលនិវត្តន៍នេះបើនៅណុងទៀតទឹកភ្លៀងចូលច្រមុះហើយ។

ក៖ អ៎ូ!

ខ៖ រួចច្រាំងបាក់ទៅលក់ទៅរួចគុណបុណ្យសម្តេចហ៊ុនសែនទេបានបានម្តុំហ្នឹង។

ក៖ អ៎ូ!

ខ៖ ចឹងហាស!

ក៖ បាទកុង! បាទចឹងមានន័យថាបងប្អូនរបស់កុងនៅផ្សេងគ្នាទាំងអស់ណោះកុងណោះ?

ខ៖ បាទនៅភ្នំពេញខ្លះនៅកំពង់ចាមខ្លះនៅត្បូងឃ្មុំខ្លះ។

ក៖ អ៎ូ!

ខ៖ នៅអាមេរិចណុងខ្លះ។

ក៖ ប៉ុន្តែបើស្រុកកំណើតយើងម៉ងនៅណាកុង?

ខ៖ ស្រុកបើខ្ញុំកើតជាមកដឹងង៉ាមកនៅភូមិមេម៉ាយយើងហ្នឹងនេះ។

ក៖ អ៎ូ! នៅកំពង់ចាមយើងហ្នឹងទេហោស?

ខ៖ បាទ! នៅកំពង់ចាមយើងហ្នឹងខ្ញុំដល់ដឹងទៅកាន់កាតាបរៀបរត់ទៅសាលានៅភូមិមេម៉ាយហ្នឹង ប៉ុនជីដូនខ្ញុំប្រាប់ថាខ្ញុំពីតូចកើតង៉ាដំបូងកើត១៩៥២ហ្នឹងកើតនៅជិតសួងទេ។

ក៖ បាទ!

ខ៖ កើតនៅជើងលងជំនាន់អ៊ីសាវ៉ាក់កើតនៅជើងលងកើតនៅជើងលងទេ។

ក៖ បាទតា!

ខ៖ ដល់គេផ្សារអាជំនាន់អ៊ីសាវ៉ាក់ហ្នឹងគេដុតផ្សារសួងណុងណាស់។

ក៖ បាទកុង!

ខ៖ ដុតផ្សារសួងណុងយាយតាខ្ញុំក៏ឈប់នៅជើងលងហ្នឹងមកនៅកំពង់ចាមនៅភូមិមេម៉ាយហ្នឹងហាស។

ក៖ អ៎ូបាទកុងបាទ!

ខ៖ ចឹងហាស!

ក៖ អ៎ូ!

ខ៖ បាទ!

ក៖ រួចចុះកុងគិតថាចឹងសម្រាប់អើឪពុករបស់កុង?

ខ៖ ឪពុកខ្ញុំទើបស្លាប់ឆ្នាំទៅឆ្នាំទៅមួយ។

ក៖ អ៎ូ! ប៉ុន្តែគាត់ឈ្មោះអីគេទៅកុង?

ខ៖ ឈ្មោះណាយអយ។

ក៖ ណាយអយ?

ខ៖ បាទ!

ក៖ មែនខ្លាយទេណាយណោះ?

ខ៖ បាទណាយ។

ក៖ ប៉ុន្តែឈ្មោះក្នុងបញ្ជីជាតិដាក់ខ្លាយវិញ?

ខ៖ អើមេឃុំគេសរសេរអោយចឹង។

ក៖ ជាប់ចឹងហាសណោះកុង?

ខ៖ ជាប់ចឹងទៅបាទឪពុកខ្ញុំឈ្មោះណាយអយទេ។

ក៖ អ៎ូ!

ខ៖ បាទ!

ក៖ រួចចុះម្តាយ?

ខ៖ ម្តាយខ្ញុំឈ្មោះគាំវ៉ាន់។

ក៖ កមវ៉ាន់?

ខ៖ គាំវ៉ាន់។

ក៖ គាំវ៉ាន់ណោះ?

ខ៖ បាទ!

ក៖ អ៎! ប៉ុន្តែគាត់អ្នកស្រុកហ្នឹងដែរណោះកុងណោះ?

ខ៖ ម្តាយខ្ញុំអ្នកស្រុកោះប៉ែនយើងនេះ។

ក៖ អ៎!

ខ៖ ឪពុកខ្ញុំអ្នកកោះសូទិនហោស។

ក៖ បាទកុងបាទ!

ខ៖ បាទ!

ក៖ ប៉ុន្តែកុងធ្លាប់មានអនុស្សាវរីយ៍ជាមួយបងប្អូនកុងកាលនៅតូចៗអត់កុងធ្លាប់ធ្វើអីគេខ្លះដែរកុងចងចាំអត់?

ខ៖ ធ្លាប់ធ្វើម៉េច?

ក៖ ចង់និយាយថាជាអនុស្សាវរីយ៍សាច់រឿងអីខ្លះជាមួយបងប្អូនយើងកាលនៅតូចៗហាស?

ខ៖ អ៎! នៅពីតូចៗមានតែអាណិតវាស្រឡាញ់វាខ្លាចប្អូនបែកចេញពីអាពតមកខ្លាចអើចេញចិតប្រាំមកចេញតាមផ្លូវខ្លាចប្អូនបែកវេទនាចឹង អប់រំវាឱ្យនៅជាមួយរហូត។

ក៖ ប៉ុន្តែប្អូនរបស់កុងហ្នឹងកើតទាន់អាជំនាន់ដែរកុងទៅជាមួយគ្នា..?

ខ៖ ហ្នឹងហើយ!

ក៖ ទៅឆ្នាំហុកជាងទាំងអស់កុងណោះ?

ខ៖ អើឆ្នាំចិតប្រាំចិតប្រាំយើងរត់អើចិតប្រាំយើងមិនរត់ចេញពីភ្នំពេញ។

ក៖ បាទកុង!

ខ៖ អើហុកសិបអីវារៀងតូចៗដឹងលេងសើចអីជាមួយគ្នាមានអី។

ក៖ អ៉ូ!

ខ៖ គ្មានដៃរធ្វើបាបអីប្អូនទេខ្ញុំហោស។

ក៖ បាទកុងត្រូវ!

ខ៖ បាទ! គ្មានអត់ដៃរធ្វើបាបប្អូនអីឱ្យពិបាកទេវាយប្អូនធ្វើអីទេ។

ក៖ អ៉ូ! បាទកុងបាទរួចចុះអើគ្រាន់ថាឥឡូវហ្នឹងពួកគាត់មានកូនមានចៅអីដូចកុងដៃរហើយណោះកុង?

ខ៖ អើវាមានកូនមានចៅអស់ហើយនេះចាំមើលខ្ញុំយករូបថតអើអានេះខ្ញុំ ខ្ញុំតាំងឱ្យមើលអើហ្វេសបុកទៅចឹងហាសអាណាធ្វើអីវាហាស។

ក៖ អ៉ូ! អត់អីទេកុង បើអត់ឃើញចាំសម្ភាសចប់ចាំយើងបើកមើលក៏បានដៃរកុង?

ខ៖ អើ!

ក៖ រួចចុះអើឪពុករបស់កុងវិញគាត់ធ្វើអីគេសម្រាប់ចិញ្ចឹមជីវិត ចិញ្ចឹមកូនចៅកាលគាត់នៅរស់?

ខ៖ ធ្វើជាងមាស។

ក៖ អ៉ូគាត់ធ្វើជាងមាស?

ខ៖ គាត់ធ្វើជាងមាស។ បាទ!

ក៖ គាត់អត់មានធ្វើស្រែចម្ការអីណាហីកុងណោះ?

ខ៖ អត់ទេម្តាយខ្ញុំអ្នកអើមេផ្ទះ។

ក៖ អ៉ូ! គាត់នៅតែផ្ទះកុងហោស?

ខ៖ បាទ!

ក៖ តែឪពុកម្តាយកុងស្លូត ឬ មួយក៏កាចកុង?

ខ៖ ម្តាយខ្ញុំស្លូតទេឪពុកខ្ញុំរៀងកាចបន្តិច។

ក៖ អ៎! បាទកុងបាទ!

ខ៖ ម៉ែចបានជាប់ចឹងកូន។

ក៖ ទៅចាំរួចទៅចាំមើលអ៎!

ខ៖ បើកអត់ចេញ។

ក៖ ចាំតិចទៀតចាំខ្ញុំឆែកអោយកុង?

ខ៖ អ៎ឃើញហើយៗ!

ក៖ រួចចុះអើកុងធ្លាប់មានសាច់រឿងអីខ្លះជាមួយឪពុកម្តាយកាលកុងនៅក្មេងអត់កុង?

ខ៖ អត់ដូចគ្មានអីទេ ព្រោះចេះបើចឹងឪពុកម្តាយក៏ហុកឆ្នាំហុកអីចឹងខ្ញុំនៅជាមួយជុំគ្នាហាសណាស់។

ក៖ បាទកុង!

ខ៖ ដល់ចិតបីចិតបួនឪពុកម្តាយខ្ញុំគាត់បែកពីជីដូនជីតាខ្ញុំមកគាត់មកធ្វើផ្ទះមួយនេះសព្វថ្ងៃផ្ទះហ្នឹងហោស។

ក៖ បាទកុង!

ខ៖ ប៉ុនគាត់រកដល់ហុកពីរហុកបីគាត់ខាតឪពុកខ្ញុំទៅនៅភ្នំពេញ។

ក៖ បាទកុង!

ខ៖ ម្តាយខ្ញុំទៅនៅភ្នំពេញដល់ឆ្នាំចិតសិបម្តាយខ្ញុំមកនៅជាមួយខ្ញុំវិញកំពង់ចាមវិញអត់មានអីពិបាកទេ។ បាទ!

ក៖ អ៎ូចឹងនៅបែកពីកុងប៉ុន្មានឆ្នាំទៅ?

ខ៖ អ៎ូគាត់នៅបែកពីខ្ញុំតាំងពីចិតតាំងពីហុកពីរ។

ក៖ បែកកុងប៉ុន្មាន?

ខ៖ ហុកពីរដល់ចិតអើចិតឪពុកខ្ញុំបែកពីខ្ញុំចិតពីរហូតដល់ចិតបី។

ក៖ អ៎ូ!

ខ៖ គាត់ទៅរកស៊ីតែភ្នំពេញហ្នឹងទេធ្វើមាសនៅភ្នំពេញហ្នឹងជាមួយនេះដន្លងគាត់ថាប្អូនខ្ញុំនៅអាមេរិចហ្នឹងហោស។

ក៖ បាទកុងបាទ!

ខ៖ បាទ!

ក៖ រួចចុះអើកុងគិតថាចឹងឪពុកគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅកុងអត់?

ខ៖ គាត់ថាពីដើមដូចគាត់ថាប្រាប់ថាពីដើម..។

ក៖ គាត់ជំនាន់បារាំងជំនាន់អ៊ីសារ៉ាក់អីហ្នឹងហោសអ៊ុំ?

ខ៖ ជំនាន់បារាំងហ្នឹង ហ្នឹងហើយជំនាន់បារាំងចាប់ធ្វើទាហ៊ានដល់ទៅច្បាំងស្រុកយួនដល់ហ្វៀនហ្វូលហោស។

ក៖ បាទកុង!

ខ៖ បាទ! ប៉ុនគាត់អត់យាយតាខ្ញុំគាត់ឱ្យឪពុកខ្ញុំចូលបួស។

ក៖ អ៎ូ!

ខ៖ អត់ចឹងទៅវាអត់ចុះធ្វើទាហ៊ានធ្វើអីទេណា៎។

ក៖ បាទកុង!

ខ៖ បាទ! បើឪពុកក្មេកខ្ញុំនេះសាត់គួងនេះឪពុកក្មេកខ្ញុំហាស។

ក៖ បាទកុងបាទ!

ខ៖ សាត់គួងគាត់ធ្វើទាហ៊ានសក្តិបីជំនាន់លន់នល់ហ្នឹងបាត់ខ្លួននៅអ្នកលឿង។

ក៖ អ៎ូបាទកុង!

ខ៖ បាទ! ឪពុកក្មេកខ្ញុំធ្វើទាហ៊ានសក្តិបីបាត់ខ្លួននៅអ្នកលឿង។

ក៖ អ៎ូ!

ខ៖ ចិតបី។

ក៖ ចុះខាងម្តាយវិញកុង?

ខ៖ ខាងម្តាយខ្ញុំ។

ក៖ ម្តាយ..?

ខ៖ ម្តាយក្មេកខ្ញុំហោស?

ក៖ អត់ទេ! ម្តាយរបស់កុងគាត់ធ្លាប់ប្រាប់ពីប្រវត្តិអីកាលគាត់នៅក្មេងៗទៅកុងអត់?

ខ៖ អត់ទេគាត់អើថាជីដូនជីតាអត់ឱ្យទៅរៀនអីឱ្យនៅផ្ទះហ្នឹងខ្លាចលាក់ដាក់លាក់នៅជង្រុកស្រូវចឹងហាស។

ក៖ អ៎ូបាទ! ប៉ុន្តែគាត់ដែលនិយាយពីអើជំនាន់បារាំងជំនាន់អ៊ីសារ៉ាក់អីអត់។

ខ៖ ម៉ែខ្ញុំមិនសូវនិយាយអីទេ គាត់មិនសូវនិយាយរឿងអីទេ គាត់គិតតែរកស៊ីចេកចាចៗវាយអីចឹងទៅធ្វើខុសអីគាត់វាយចឹងទៅ អីទៅតែជីដូនខ្ញុំទេជីដូនខ្ញុំទេគាត់នេះ។

ក៖ អ៎ូបាទកុង!

ខ៖ នេះឪពុកខ្ញុំហោសឪពុកខ្ញុំអានេះម្តាយក្មេកខ្ញុំ។

ក៖ អ៉ូ!

ខ៖ ម្តាយក្មេកខ្ញុំហ្នឹងត្រូវជាប្អូនម្តាយខ្ញុំហ្នឹងហាស។

ក៖ អ៉ូ! នៅទាល់ឥឡូវហ្នឹងកុងហោស?

ខ៖ ម្តាយក្មេកខ្ញុំនៅទាល់តែឥឡូវ។

ក៖ អ៉ូ!

ខ៖ ចិតកៅជាងហើយឥឡូវហោសនោភ្នំពេញហោស។

ក៖ បាទ! យូរហើយណេះកុងណេះ?

ខ៖ ឪពុកខ្ញុំស្លាប់ឆ្នាំទៅគាត់ខួចឆ្នាំទៅហើយ។

ក៖ អ៉ូ! គាត់នៅតែរស់បានទាល់ឥឡូវ អ៉ូរួចចុះកុងគិតថាយាយតាខាងឪពុកឈ្មោះអីគេកុង?

ខ៖ យាយតាខាងឪពុកខ្ញុំហោស?

ក៖ បាទ!

ខ៖ ឈ្មោះយាយ..។

ក៖ ឈ្មោះតាណាយមែនកុង?

ខ៖ ឈ្មោះតាណាយហើយយាយយែម។

ក៖ តាណាយយាយយែម?

ខ៖ បាទ!

ក៖ ចុះអើយាយតាខាងម្តាយ?

ខ៖ យាយតាបង្កើតខាងម្តាយហោស?

ក៖ បាទឈ្មោះតាគាំ។

ខ៖ អើតាគាំប៉ាត់តាណុងឈ្មោះតាគាំប៉ាត់។

ក៖ តាគាំប៉ាត់?

ខ៖ បាទ!

ក៖ រួចចុះអើយាយ?

ខ៖ យាយឈ្មោះយាយប៉ាច។

ក៖ អ៎ូ!

ខ៖ ប្រាំងប៉ាច។

ក៖ ប្រាំងប៉ាច?

ខ៖ បាទ!

ក៖ ចឹងមានន័យថាអើកុងចាំយាយតាបន្តទៀតអត់?

ខ៖ យាយតាបន្តទៀតម៉េច?

ក៖ ចង់និយាយថាអើយាយតារបស់កុងហាសយាយតាទួតរបស់កុងទៀតកុងស្គាល់?

ខ៖ អត់អត់ស្គាល់។

ក៖ អត់ស្គាល់ទេណោះកុងណោះ?

ខ៖ បាទ! គាត់ខូចមុនហ្នឹងហើយ។

ក៖ អូចឹង..?

ខ៖ គាត់ខូចមុនហើយគាត់ខូចអស់ហើយយាយទួតតាទួតខូចអស់ហើយ។

ក៖ ចឹងមានន័យថាយាយតាកុងគ្រាន់តែចាំប៉ុន្តែកុងទាន់ពួកគាត់ទេ?

ខ៖ ឪពុកពីណា?

ក៖ និយាយទាន់យាយតាខាងឪពុកខាងម្តាយអត់កុងកើតមកទាន់ពូកគាត់អត់?

ខ៖ អត់ទាន់ទេទាន់តែប៉ុណ្ណឹងទាន់យាយប៉ាច យាយប៉ាចតាប៉ាត់ហើយហ្នឹងយាយយៃមតាណាយហ្នឹង។

ក៖ អ៎ូកុងទាន់តែប៉ុណ្ណឹងទេណោះកុង?

ខ៖ បាទ! ទាន់តែប៉ុណ្ណឹង។

ក៖ អ៎ូ!

ខ៖ បើតាទួតយាយទួតអត់ស្គាល់ទេ។

ក៖ អ៎ូ!

ខ៖ ប៉ុនមានរូបថតមានរូបថតអើមានមាខ្ញុំមួយនេះគាត់នៅបារាំងគាត់ថាខ្ញុំដូចតាបារាំងហាសនេះរូបខ្ញុំកាលចិតសិបមួយចិតពីរឿនទីពីរហោស។

ក៖ អ៎ូបាទកុង!

ខ៖ មើលទៅស្គាល់ទេដឹងឥឡូវហ្នឹងឥឡូវមើលគាត់។

ក៖ ខ្ញុំមើលអត់ស្គាល់ដោយសាររូបថតកាលជំនាន់ណុងវាប្លែក។

ខ៖ នេះរូបហ្នឹងខ្ញុំបានពីពូកម៉ាកខ្ញុំមួយនេះអាប្រាប់ខ្ញុំថាកុំប្រាប់គេថាធ្វើទាហ៊ានធ្វើអីអានេះៗ។

ក៖ ចុងគេ?

ខ៖ អាណៅហឿនអាទីពីរអាក្រោយ។

ក៖ នេះហ្នឹងហោសកុង?

ខ៖ បាទៗ!

ក៖ អ៎ូ!

ខ៖ អាណុងហាស!

ក៖ បាទកុង!

ខ៖ បាទ! អាហ្នឹងអាប្រាប់ខ្ញុំបាទអានេះឮថាធ្វើធំហាសណាំខាងមុខនេះប៉ុនគ្រាន់ដឹងទេធ្វើធំហាសណាំសុទ្ធតែធ្វើធំទាំងអស់ ហ្នឹងនៅបើអានៅពីក្រោយខ្ញុំនេះជាងក្រឡឹងកំពង់ចាមនេះ។

ក៖ អ៎ូ!

ខ៖ អានេះងាប់ហើយអានេះធ្វើអាម៉ារីនធ្វើទាហ៊ានអាម៉ារីននេះ។

ក៖ អ៎ូបាទកុង!

ខ៖ នៅតែនៅព្រៃទទឹងប្រាប់គេត្រង់គេវ៉ៃចោល។

ក៖ បាទកុងបាទ!

ខ៖ បាទចៃហឿនចៃអានេះអាហាន់មិនដឹងធ្វើអីទេប៉ុនស្លាប់ហើយ។

ក៖ បាទកុងបាទរួចចុះកុងចឹងកុងគិតថាកុងមករស់នៅហ្នឹងរយៈពេលប៉ុន្មានឆ្នាំហើយកុង?

ខ៖ នៅនេះ?

ក៖ មកនៅហ្នឹង។ បាទ!

ខ៖ ប្រាំមួយឆ្នាំហើយ!

ក៖ ប្រាំមួយឆ្នាំហើយណោះកុង?

ខ៖ តាំងពីបងធ្វើផ្ទះណុងមកបន្តិបមកខ្ញុំមកណោះដែរធ្វើផ្ទះនៅដែរ។

ក៖ អ៎ូ! ចុះអើកុងអាចប្រាប់ពីការលំបាកដែលកុងចាប់ដៃជាមួយម៉ាបានទេកុងជាមួយប្រពន្ធរបស់កុង?

ខ៖ ខ្ញុំ។

ក៖ យើងមានការលំបាកអីពេលណុងជំនាន់ណាកុងកុងកាលការណុងជំនាន់ណា?

ខ៖ ជំនាន់អើចិតប្រាំបីមានពិបាកឮមានអីពិបាកថាចាប់ដៃទៅអង្គការគេឱ្យចាប់ដៃគ្នាទៅហូបបាយសម្លកកូរមួយចាន ចូលក្នុងផ្ទះជីដូនជីតាម៉ែឪសែនព្រេនទៅរស់នៅជាមួយគ្នាទៅ។

ក៖ អ៎ូ!

ខ៖ រួចជំនាន់ណុងមានអីពិបាករួចគោក្របីកាលណុងគេរត់ចោលភូមិទៅបានក្របីមួយនឹមចិញ្ចឹមទៅ រួចអើដល់ទំនេរឆ្លៀតធ្វើរទេះធ្វើអីជាមួយគេទៅបានរទេះមួយផ្ទឹមទៅដល់ចិតប្រាំបួនបានរទេះបានក្របីហ្នឹងគេធ្វើដូចអ្នកស្រែចម្ការចឹង។

ក៖ អ៎ូបាទកុង!

ខ៖ អត់មានដៃរនៅកាំរកោសគ្នាអីទេ។

ក៖ អ៎ូ! អាហ្នឹងអ្វីដែរកុង ប៉ុន្តែកុងគិតថាពេលឆ្នាំណាដែលយើងគិតថាចាប់ផ្តើមស្រុកស្រួលសប្បាយវិញកុងលែងមានសង្គ្រាម?

ខ៖ បើអើបើចិតប្រាំបួនថាខ្លាចយួនអីចឹងហាសណា៎។

ក៖ បាទកុងបាទ!

ខ៖ បាទ! ដល់បោះឆ្នោតហើយដូចជាស្រួលតែម៉ងហាស។

ក៖ នៅឆ្នាំកៅបីហោសកុង?

ខ៖ បាទ!

ក៖ ឧន្តាក់ហ្នឹងហី?

ខ៖ ហ្នឹងហើយឧន្តាក់ បើជំនាន់ចិតប្រាំបួនយើងខ្លាចតែវាចោទយើងចេះចុះៗប៉ុនវាចោទអីបើខ្ញុំធ្វើគ្រូបង្រៀនគ្មានទេ គេឱ្យយើងបង្រៀនអីយើងបង្រៀនណុងទៅអីទៅគ្មានស្អីសោះ។

ក៖ អត់អីដែរណោះកុង?

ខ៖ បាទ! មានទៅប្រឆាំងហ្នឹងគេអើបើឮដែរ អាខ្លះធ្វើប្រឆាំងគេណុងគេចាប់ហាសគ្រូខ្លះហាស។

ក៖ បាទកុង!

ខ៖ ប៉ុនខ្ញុំអត់មានទៅប្រឆាំងនេះស្រីៗរៀនជាមួយខ្ញុំហោស។

ក៖ អ៎ូ!

ខ៖ អ្នកនេះស្លាប់ហើយអាកណ្តាលនេះអានេះស្លាប់ហើយនៅបីនាក់។

ក៖ អ៎ូប៉ុន្តែពួកគាត់នៅណាទៅកុង?

ខ៖ អានេះនៅភ្នំពេញហោសប៉ុនមិនដឹងគេធ្វើការអីទេអានេះអ្នកយករូបថតមកអោយខ្ញុំអានេះអាស្រីនេះអាតូចហោស។

ក៖ គាត់នៅចងចាំទាល់ឥឡូវ?

ខ៖ បាទ!

ក៖ រូបថត?

ខ៖ រួចទៅអានេះក៏ថានៅក្រចេះអានេះអាចុងនេះនៅក្រចេះ។

ក៖ អ៎ូ បាទកុងបាទ!

ខ៖ រួចមករៀនសាលាទិនចិនមួយឆ្នាំមួយវគ្គហ្នឹងមានតែប្រាំនាក់ហ្នឹងទេរៀនជាមួយគ្នា។

ក៖ អ៎ូ!

ខ៖ អានេះឪពុកវាធ្វើទាហ៊ានៅស្លាប់ ស្លាប់ជំនាន់គេកំពុងតែរៀនគ្នាពិបាកហាសអាណិតគ្នាជាងគេឪពុកធ្វើទាហ៊ានទៅដល់នេះគេច្បាំងហាសច្បាំងគាត់ស្លាប់ហាសចិតប្រហែលចិតមួយស្លាប់។

ក៖ បាទកុងបាទ!

ខ៖ អានេះទេពជាវ៉ាត។

ក៖ អ៎ូ!

ខ៖ បាទ!

ក៖ ប៉ុន្តែអើដូចជាសាលាទិនចិនហ្នឹងនៅណាកុង?

ខ៖ ហៅនេះវិទ្យាល័យហ៊ុនសែន។

ក៖ អ៎ូ!

ខ៖ បឹងកុកហ្នឹងហាស។

ក៖ បឹងកុកយើងហ្នឹងហេស?

ខ៖ មុនគេហៅចេះពីក្មេងតូចគេហៅថាសាលាជាង។

ក៖ បាទកុងបាទ!

ខ៖ ពីដើមហៅសាលាជាងដល់ក្រោយមកទៀតគេហៅសាលាអើសាលាដែក។

ក៖ បាទកុង!

ខ៖ ដល់ខ្ញុំពេញកម្លោះពេញរូបទៅគេហៅសាលាទិចនិច។

ក៖ អ៎ូ!

ខ៖ ដល់គេបង្កើតសាកលវិទ្យាល័យកំពង់ចាមទៅគេដាក់លែងហៅសាលាទិចនិចហើយគេហៅ មហាអើមហាវិទ្យាល័យយូនវិទ្យា។

ក៖ អ៎ូ!

ខ៖ បាទ!

ក៖ បាទកុងបាទ!

ខ៖ បាទចឹងហាស!

ក៖ បាទ!

ខ៖ មុនដំបូងគេហៅតែសាលាជាងទេអើដល់អស់ពីសាលាជាងទៅហៅសាលាដែក។

ក៖ បាទកុង!

ខ៖ សាលាដែកដល់ខ្ញុំពេញកម្លោះទៅហ្នឹងគេហៅសាលាទិចនិច។

ក៖ បាទកុង!

ខ៖ បាទ! ដល់ពេលជំនាន់គេបង្កើតសាកលវិទ្យាល័យកំពង់ចាមភូមិមិន្ទកំពង់ចាមអើទន្លេអ៊ុំហ្នឹងហោស។

ក៖ បាទកុងបាទ!

ខ៖ គេយកសាលាជាងហ្នឹងសាលាទិចនិចហ្នឹងបញ្ចូលជាសាខាកូនសាខាសាលាសាកលវិទ្យាល័យហ្នឹងហាស។

ក៖ បាទកុងបាទ!

ខ៖ ជាសាលាកំពង់ចាមហ្នឹងដាក់មហាវិទ្យាល័យយួនវិទ្យា។

ក៖ អ៎ូ!

ខ៖ បាទ!

ក៖ ប៉ុន្តែអើកុងពេលជំនាន់ណុងកុងរៀនបានថ្នាក់ទីប៉ុន្មានទៅកុង?

ខ៖ កាលណុងមើលឆ្នាំចិតសិបខ្ញុំជាប់ឌីប្លូម។

ក៖ អ៎ូ!

ខ៖ ចប់ឌីប្លូមដល់ឌីប្លូមទៅនឹកថាចេះថាចូលសាលាទិចនិចហ្នឹងវារៀនបច្ចេកទេសណា៎។

ក៖ បាទកុង!

ខ៖ ម៉េចមកយើងបានរៀនអាបច្ចេកទេសទៅ ចូលរោងធ្វើការរោងចក្រក្រណាតរោងចក្រអីចឹងទៅ រោងចក្រក្រដាសឆ្លងអីចឹងទៅណាស់យើងធ្វើខាងបច្ចេកទេសហាស។

ក៖ បាទកុង!

ខ៖ អើយើងបានធ្វើចឹងមិនទៅជាគ្រូអីទេកាលណុងរៀនដូចជាដឹងខ្សោយមិនពូកែណាស់ណាដូចគេហាស។

ក៖ បាទកុង!

ខ៖ គិតថារៀនអាហ្នឹងទៅយើងបានជំនាញចឹងហាស។

ក៖ បាទៗកុង!

ខ៖ ដល់ពេលស្រុកចូលផ្តុកបានរៀននេះស្រុកកើតសង្គ្រាមទៅមានបានចេះអីទិចនិចនោះ។

ក៖ អ៎ូ!

ខ៖ ខ្ញុំរៀនជាងខាងធ្វើឡានខ្ញុំបច្ចេកទេសខាងធ្វើឡាន ប៉ុនឥឡូវឱ្យដោះឡានមើលអស់ខ្លៅរលីង។

ក៖ បាទ! កុងរួចចុះកុងជំនាន់កុងបានរៀនបារាំងអត់កុង?

ខ៖ រៀន។

ក៖ បានរៀនបារាំងដែរហោស។

ខ៖ ជំនាន់ខ្ញុំបារាំងចុងក្រោយគេហើយ។

ក៖ អ៎ូ!

ខ៖ ជំនាន់ខ្ញុំហ្នឹងបារាំងចុងក្រោយហើយបន្ទាប់ខ្ញុំទៀត..។

ក៖ គេលែងរៀនហើយណោះ?

ខ៖ គេរៀនខេមរយាន្តកម្មម្តង។

ក៖ អ៎ូ!

ខ៖ យាន្តទាំងអស់ជាខ្មែរទាំងអស់ហាស។

ក៖ បាទកុង!

ខ៖ ព្រោះជំនាន់ខ្ញុំមានតែភាសាខ្មែរទេដែលជារៀនខ្មែរ បើជីវៈអីភូមិវិទ្យា ប្រវត្តិវិទ្យា គណិតអីសុទ្ធតែបារាំងទាំងអស់។

ក៖ អ៎ូបាទ!

ខ៖ សុទ្ធតែបារាំងទាំងអស់។

ក៖ បាទកុងបាទ!

ខ៖ ដល់បារាំងចឹងដល់ខ្លួនឯងហ្នឹងខ្លួនឯងខ្សោយរៀនសាលាទិចនិចទៅគីឡូបានម៉ែចមកបានរៀនខាងជាងហ្នឹងហើយ។

ក៖ អ៎ូ! បាទកុងចុះកុងគិតថាកាលជំនាន់កុងរៀនហ្នឹងនៅមានមិត្តភក្តិច្រើនតើហ៊ីដែរនៅជាមួយនៅរស់ដូចកុងដែរ?

ខ៖ នេះហ្នឹងបានថាមិត្តភក្តិប៉ុនមើលចាំខ្ញុំយករូបថតឱ្យមើល។

ក៖ ប្រាប់គាត់ថាចាំពេលក្រោយចឹងទៅ?

ខ៖ ហ៊ីអានេះគម្តីរផ្នត់គំនិតសម័យ សម័យអើខ្លះគេអួតចេះអួតចុះថាមិនប្រឆាំងគេទេ ប៉ុន្តែកុំមកជាន់ថាបើហែងពូកែហែងចិតប្រាំបួនមានអញដែរតើ មែនតែហែងអីណា ខ្ញុំថាចឹងខ្ញុំគិតសព្វៗខ្ញុំគិតចឹងថាដូចថាយើងធ្វើការងារចឹងហាណា៎ គេរបៀបគេមើលងាយដូចថាយើងអន់ជាងវាចឹងហាសណា៎។

ក៖ បាទកុង!

ខ៖ ខ្ញុំថាហៅអញមែននេះទេហាស៧៩ កុំបាន៧៩អញដែរទេ ហើយនេះឬនេះអាហ្នឹងវាយកមកឱ្យអានេះៗវាយកមកឱ្យខ្ញុំហោស។

ក៖ បាទកុងបាទ!

ខ៖ អានេះៗ។

ក៖ អ៎ូនេះ?

ខ៖ នេះហ្នឹងហើយសាលាហ្នឹងហាសពីដើមហោស។

ក៖ បាទកុង!

ខ៖ នេះពួកម៉ាករៀន។

ក៖ សុទ្ធតែមិត្តភក្តិកុងដែរៀន?

ខ៖ ហ្នឹងមួយជំនាន់ខ្ញុំហ្នឹងហើយជំនាន់៧០ហោស។

ក៖ ប៉ុន្តែកុងគិតថាអើពួកគាត់ឥឡូវនៅណាអស់ទៅកុង?

ខ៖ បាទ! ទាំងអស់នេះហោស។

ក៖ ទាំងអស់ហ្នឹងពួកគាត់នៅណា?

ខ៖ អ៎ូ! អត់ដឹងគេយើងទាំងអស់គ្នាជំនាន់ចិតប្រាំហ្នឹងទៅហើយមិនដឹងទៅណាណីមិនដឹងរស់មិនដឹងស្លាប់។

ក៖ អ៎ូ! បាទកុងបាទហើយចុះកុងគិតថាកុងធ្លាប់មានអនុស្សាវរីយ៍អីខ្លះជាមួយមិត្តភក្តិកាលកុងនៅរៀនអត់កុង?

ខ៖ មិត្តភក្តិដូចខ្ញុំនិយាយចឹងថាស្រឡាញ់គ្នា ធម្មតាទុកចិត្តគ្នាទៅវិញទៅទៅមកចឹងហាសណា៎។

ក៖ បាទកុង!

ខ៖ ដូចអានេះចឹងហាសណ៎ាដូចវារត់ទៅដល់ជម្លៀសទៅរត់ទៅផ្សេងៗដល់ជុំជួបគ្នានាំគ្នាប្រាប់រឿងរ៉ាវអស់ហ្នឹងហាស ខ្ញុំនឹកថាស្រុកគេខ្លាំងឈ្លោះគ្នាថ្ងៃក្រោយវាចប់សង្គ្រាមលែងកាប់ចាក់គ្នាហើយណាស់។

ក៖ បាទកុង!

ខ៖ អើចឹងហាណ៎ា។

ក៖ បាទ!

ខ៖ ប៉ុនដល់វា៧៩ទៅ វានៅអារកមុខអានេះចក្រព័ទ្ធអានេះឈ្លើយសឹកខ្មែរដូចគ្នាហៅឈ្លើយសឹកដូចអីខ្ញុំហួសចិត្តម៉ងហួសចិត្តហាសឮថ្ងៃហ្នឹងហាស។

ក៖ អ៎ូ!

ខ៖ អើរួចដល់ចឹងទៅរួចដល់យើងធ្វើឡេឡឺមិនមាត់មិនកធ្វើឆ្លូតធ្វើឡប់លេខទៅក៏ស្រួលដែរដល់ពេលណុងវាអត់សូវប្រើយើងវិញហាស។

ក៖ បាទកុង!

ខ៖ ដល់អើឆ្នាំ៧៥-៧៩ហ្នឹង គេឱ្យវាដល់ពេលខ្ញុំឈឺចឹងទៅងើបពីជាអត់ឱ្យគេរកបាយស៊ីឱ្យវេចបាយមួយកញ្ចប់ទឹកមួយបំពង់ឱ្យទៅទឹកមួយបំពង់មួយកន្តុងចឹងហាសណ៎ា។

ក៖ បាទកុង!

ខ៖ ទៅព្រៃកាប់អូសដាក់រទេះលើកអូសដាក់រទេះមកអោងបាយ។

ក៖ អ៎ូ!

ខ៖ ដល់ថ្ងៃត្រង់ម៉ោងបីម៉ោងបួនយើងសម្រាកពេលបាយថ្ងៃត្រង់រួចយើងអារអូសកង់ៗឱ្យគេដាក់រោងបាយឱ្យគេទៅ ដល់ព្រលឹមឡើងយើងទៅព្រៃអត់មានជាប់ទាក់ទងអីវេរកស្គាល់ពីណាទាំងអស់។

ក៖ អ៎ូ!

ខ៖ អ៎ូចឹងហាស!

ក៖ បាទកុងបាទ!

ខ៖ កាលជំនាន់ណុងហាស បើជំនាន់អាពតហ្នឹងហាស បើជួនណាយើងធ្វើស្រូវធ្វើចម្ការជាមួយគ្នាប្តីប្រពន្ធ ឬក៏ស្គាល់គ្នាស្គាល់អីចឹងហាស មិនស្រួលអើធ្វើអីហាសអានេះថាអានេះចឹងទៅចឹងយកទៅបាត់ទៅ។

ក៖ បាទកុង!

ខ៖ អើច្រឡំទៅបាត់ចឹងហាស វាចឹងដល់ចឹងស្រួលវិញអត់អី។

ក៖ អត់នៅក្បែរគ្នា?

ខ៖ អត់នៅក្បែរគ្នាអត់មានពីណាពីណី។

ក៖ ចឹងកុងនៅបែកគ្នាជាមួយមិត្តភក្តិទាំងអស់គ្នាណោះកុងណោះ?

ខ៖ បាទអត់មានទេ។

ក៖ អ៎ូ!

ខ៖ រួចអ្នកថ្មីជំនាន់ណុងដូចខ្ញុំមិនសូវធ្វើស្គាល់គ្នាម៉ងខ្លាចហាស។

ក៖ ចា៎ស!

ខ៖ ខ្លាចវាដឹងរឿងទៅវាចាក់ចុចគ្នាបង។

ក៖ បាទ! កុងបាទ ត្រូវហើយ ចុះកុងគិតថាអើចឹងស្រែចម្ការកុងធ្លាប់ធ្វើណេះកុងណេះជំនាន់ណុង?

ខ៖ អើជំនាន់ស្វួងស្រែបោកចឹងទៅបោកស្រែធ្វើឱ្យប្រឡាក់ប្រឡូសអស់ទៅបោកដាក់អរណាស់ ព្រោះយើងកាលណុងយើងធ្វើទាហ៊ាន។

ក៖ បាទកុង!

ខ៖ វាពាក់យឺតខាងក្នុងដៃខ្លីរួចកណេះរួចពាក់អាវទាហ៊ានពីក្រៅដល់ក្តៅស្អុះដកអាខោអាវទាហ៊ានចេញទុកតែប៉ុណ្ណឹងទៅវាមិនក្តៅនេះ ដល់យើងដល់ចិតក្រាំបានយើងដោះអាវចោលដោះអាវចោលវាយើញយើងសពពាលពពាលហោស។

ក៖ ចាស!

ខ៖ ថាយើងអ្នកស្រណុកហើយសូរថាខ្ញុំអ្នកស្រណុកអីណាខ្ញុំលីផែមកនៅផ្សារចាស់ហោស។

ក៖ បាទកុង!

ខ៖ អើផ្ងតគេចឹងទៅណាស់ដល់ចឹងវាក្តៅពេកយកឱ្យអាវយឺតពាក់ទៅ ប៉ុនឥឡូវអាវយឺតនៅណាបោះក្រវាត់ចោលរហែកអស់ហើយចឹងរួចខ្លួនទៅ រួចដល់បោកសំណាបបោកអីឱ្យវាបោកប្រឡាក់ទៅស្រួលចឹងទៅខែបួនក្រាំខែបានបាត់អាពពាលហ្នឹងហាស។

ក៖ អ៎ូ!

ខ៖ បាទ!

ក៖ រួចចូលចំណោមគេចុះណេះកុង?

ខ៖ បាទ! បានចូលចំណោមគេចុះហាសបន់ឱ្យគេបោកដាក់ទេ។

ក៖ អ៎ូ!

ខ៖ រួចអ្នកថ្មីខ្លះបោកបាំងៗដីខ្មៀតចូលខ្លួនគេ គេស្រែកឱ្យហាសខ្ញុំធ្វើមិនដឹងបោសម៉េចបោសទៅតែបោសប្រឡាក់ៗទៅរួចទៅញីដាក់ផុកលើខ្លួនឱ្យខ្មៅឃ្លីចក្របី។

ក៖ រួចចុះកុងអើកុងធ្លាប់ចិញ្ចឹមសត្វចិញ្ចឹមអីអត់ជំនាន់ណុងកុង?

ខ៖ ជំនាន់អាពតហោស?

ក៖ ទាំងជំនាន់លន់នល់ជំនាន់អាពតជំនាន់អី?

ខ៖ អើជំនាន់អាពតគិតពីរៀនហោសរៀនរួចច្បាំងគ្នាមានដែលចិញ្ចឹមអី។

ក៖ អត់ដែលចិញ្ចឹម?

ខ៖ ចិញ្ចឹមតែឥឡូវហ្នឹងទេអាកូនវាយកមកចិញ្ចឹម។

ក៖ ចិញ្ចឹមមាន់ទា?

ខ៖ ចិញ្ចឹមមាន់តើ។

ក៖ អ៎! បាទកុង ចុះកុងគិតថាតាំងពីក្មេងហាសកុងធ្លាប់ធ្វើការងារគេខ្លះរហូតកុង?

ខ៖ កាលពីក្មេងរៀនរៀនរួចធ្វើទាហ៊ានណុងហាស។

ក៖ ធ្វើទាហ៊ានម៉ងហោស?

ខ៖ បាទ!! ធ្វើទាហ៊ានមកធ្វើស្រែជំនាន់អាពតណុង ដល់អាពតចប់៧៩រៀតណាមទៅវើសបោះឆ្នោតប្រធានភូមិ។

ក៖ បាទកុង!

ខ៖ បានប្រធានភូមិប្រធានភូមិតែងតាំងខ្ញុំធ្វើគ្រូបង្រៀនគ្រូបង្រៀនតាំងពីណុងមក តាំងពី៨៣ តាំងពី៧៩ណុងមក។

ក៖ អ៎!

ខ៖ បាទ! កាលណុងអត់មានប្រាក់ខែទេ មុនដំបូងរួចចែកអង្ករហាសចែកអង្ករពូជសម្លីហាស រួចខ្មែរគិតទៅដូចវាសំណាងខ្លួនឯងអ្នកស្រុកធ្វើស្រូវខ្ញុំបានស៊ីហាស។

ក៖ ចាំស!

ខ៖ ខ្ញុំដល់ខែបានស្រូវពោតសម្លីមកដាំបាយដាំអីស៊ីទៅចឹងហាស។

ក៖ អ៎ំបាទកុង!

ខ៖ ម៉្យាងដៃរួចទៅបានទឹកដោះគោទឹកដោះអីមកឆុងចែកចាស់ៗក្នុងភូមិមួយសារចឹងទៅ។

ក៖ អ៎ំ!

ខ៖ អារឿងថារឿងបើនិយាយឱ្យអស់ទៅរឿងពិបាកលំបិនដុតដៃដុតជើងដូចមិនពិបាកដូចស្រួលម៉្យាង។

ក៖ អ៎ំបាទកុងបាទ!

ខ៖ បាទ!

ក៖ ចុះកុងគិតថាជីវិតរបស់យើងមានការផ្លាស់ប្តូរអីគេខ្លះទៅកុង តាំងពីក្មេងរហូតមកដល់ឥឡូវ កាលកុងនៅជាមួយឪពុកម្តាយជីវិតយើងម៉េច?

ខ៖ កាលនៅជាមួយឪពុកម្តាយមានគិតរកស៊ីអីគិតតែដល់ម៉ោងស៊ីបាយម៉ែដាំបាយឱ្យចូលស៊ីបាយទៅ ហើយជួយបើថានេះទេគាត់ពិបាកគាត់ហៅជួយលាងចានបើមិនពិបាកទេ ដើរលេងទៅគ្មានអី។

ក៖ អ៎ំ!

ខ៖ ដល់ឆ្នាំ៧០ទៅរៀនទៅចូលសាលាទិចនិចស្រុកច្បាំងគ្នាទៅម្តាយហ្នឹងក៏ពិបាករកឪពុកខ្ញុំទៅភ្នំពេញចឹងទៅចេះទៅដល់ណុងម៉្យាងដែរ។

ក៖ ចាំស!

ខ៖ រួចដល់ឆ្នាំ៧០ហ្នឹងចូលសាលាទិចនិចហ្នឹងគេរើសកម្ម៉ងដូរ។

ក៖ បាទកុង!

ខ៖ បើនិយាយឱ្យអស់ទៅយើងធ្វើខ្ញុំទេ ធ្វើទាហ៊ានតាំងពីឆ្នាំ៧០ម៉េស គេឱ្យស្ពាយកាំភ្លើងកាe ន់តែយប់យាមសាលា។

ក៖ បាទកុង!

ខ៖ ថ្ងៃរៀនធម្មតា។

ក៖ អ៎ូ!

ខ៖ ថ្ងៃរៀនធម្មតាដូចគេដូចឯងចឹងដល់យប់រៀនសាលាបានម៉្យាងដៃរវាមិនបានទៅច្បាំងជាមួយគេជាមួយឯងនៅណាទេ គ្រាន់ថាអើជួនណាគេមានការហៅយើងមួយហ្វូងទៅកាន់កាំភ្លើងដើរត្រៀសពស់ត្រៀសអីទៅណា៎។

ក៖ បាទកុង!

ខ៖ ដល់អីអើនាងហ៊ីងនាងអីចឹងកាលណុងហោស។

ក៖ បាទ!

ខ៖ រួចកាលជំនាន់៧០ហាស ពេញកម្លោះកំពុងពេញសប្បាយហាសណា៎ ខាងកើតបានត្រឹមមាត់ទន្លេទេខ្ញុំ។

ក៖ អ៎ូ!

ខ៖ ឆ្លងទន្លេទៅរួចទន្លេបិទជីវោទ៍អាពត ហើយបើខាងជើងវិញអើខាងត្បូងវិញបានត្រឹមនេះទេណាស់ត្រឹមអើតាមៀង។

ក៖ អ៎ូបាទស្គាល់?

ខ៖ ត្រឹមតាមៀងទេ ផុតត្រឹមតាមៀងមានខ្សែត្រៀមអាពតទៀតហើយ។

ក៖ អ៉ូ!

ខ៖ រួចបើខាងជើងនេះវិញបានត្រឹមបល្ល័ងទេណា៎ បល្ល័ងយើងហ្នឹងហាស។

ក៖ បាទកុង!

ខ៖ កាលណុងមើលម្តងប្រហែលចិតពីរចិតមួយ ចិតពីរជិះកាត់តាមណុងកាត់បន្ទាយទាហ៊ានហែលមកធ្វើអីអើខ្ញុំជិះម៉ូតូកង់ជើរលេង ហើហែងឥឡូវគ្រាន់ហែងច្បាំងគ្នាគ្មានដឹងស្អីគិតសប្បាយកាលណុងត្រឹមបល្ល័ងហ្នឹង!

ក៖ អ៉ូ!

ខ៖ បល្ល័ងកាលនេះកាលជំនាន់ចិតបីពូកខ្មែរក្រហមចូលតាមហ្នឹងហាស!

ក៖ បាទកុងបាទ!

ខ៖ កន្លែងនេះសុទ្ធតែព្រៃទាំងអស់គ្មានផ្ទះក្បឿងគ្មានស្អីទេព្រៃហាស អើបើមាត់ទន្លេវាចូលមកដំបូងវាចូលតាមអើវាចូលទៅខាងចុងថ្ពល់ហោសប៉ុនយន្តហោះទម្លាក់គ្រាប់បែកដាច់អានោះចុងថ្ពល់ទៅវាងាកមកវិញចូលតាមចំហៀងនេះអើថ្មគោលនេះ។

ក៖ បាទកុង!

ខ៖ អាផ្លូវអីធ្វើផ្លូវគ្រោះហោស។

ក៖ បាទកុងបាទ!

ខ៖ ផ្លូវកៅស៊ូថ្ពល់ហ្នឹងហាសចូលតាមហ្នឹងហាស។

ក៖ អើ!

ខ៖ រួចបើនេះវាមកតាមនេះតាមហ្នឹងយកតាមហ្នឹងដែរ ប៉ុនដល់ទាហ៊ាននេះទាហ៊ានវាលវង់យន្តហោះហោស។

ក៖ បាទកុង!

ខ៖ ចុះមកទប់ទៅវាមកតាមផ្លូវហ្នឹង។

ក៖ អ៎ូ!

ខ៖ ដើរតាមផ្លូវហ្នឹងដល់នេះតាមផ្លូវហ្នឹងអើហ្នឹងយន្តហោះទម្លាក់ងាប់ច្រើនហាសទីហ្នឹងហាស។

ក៖ អ៎ូនៅហ្នឹងហោសកុង?

ខ៖ អើត្រង់យើងនេះហៅអីហ្នឹងគេហៅក្រោយលីវ។

ក៖ បាទកុង!

ខ៖ ថ្មត្រប៉ែតទម្លាក់គ្រាប់បែកខ្លាំងហាសណា៎កន្លែងហ្នឹង។

ក៖ អ៎ូបាទកុង!

ខ៖ ឆ្នាំ៧៣ហាស!

ក៖ បាទ! ចុះកុងគិតថាចឹងសម្រាប់ដូចជាកុងមានបងប្អូនកូនចៅណាដែលពួកគាត់ចេះលេងឧបករណ៍ភ្លេងទេកុង?

ខ៖ អត់ទេ។

ក៖ អត់ទេណោះកុង?

ខ៖ បានអត់មានទេ។

ក៖ រួចចុះកុងគិតថាអើកាលពីក្មេងហាស?

ខ៖ អើ!

ក៖ កុងគិតថាផ្ទះរបស់កុងនៅជាមួយឪពុកម្តាយផ្ទះបែបណាកុង?

ខ៖ ផ្ទះក្បឿង។

ក៖ ផ្ទះក្បឿងប៉ុន្តែកាលណុងនៅណាកុង?

ខ៖ បាទ! នេះនៅម្តុំក្រោយវត្តជ្រោយថ្មនេះ។

ក៖ អ៎ូ!

ខ៖ រួចដល់អើឆ្នាំ៦០បានខ្ញុំមកនៅជាមួយឪពុកម្តាយខ្ញុំបែកពីជីដូនជីតាខ្ញុំមកមកនៅត្រង់នេះ គ្រាន់តែរំលងមួយផ្លូវទេណា៎។

ក៖ បាទកុង!

ខ៖ នៅសព្វថ្ងៃផ្ទះនៅសព្វថ្ងៃឥឡូវនេះ។

ក៖ អ៎ូ! ប៉ុន្តែយើងលក់ឱ្យគេហើយណោះកុង?

ខ៖ បាទ! លក់ឱ្យគេហើយ។

ក៖ អ៎ូ!

ខ៖ ម្ចាស់គេផ្សេង។

ក៖ បាទ! កុងបាទរួចចុះកុងគិតថាឪពុកម្តាយរបស់កុងធ្លាប់បង្រៀនពីជំនាញអីទៅកុងអត់?

ខ៖ អត់ទេឪពុកខ្ញុំ បើខ្ញុំគាត់ធ្វើមានហាសបើសិនខ្ញុំទៅក្បែរគាត់ទៅកាន់ញញួរដុំស្ពឹៗហ្នឹងដូចលេងអីកំប៉ិកកំប៉ុកកន្លែងជាងគាត់ហាស កន្លែងគាត់ហាសគាត់ដេញខ្ញុំចេញហើយ។

ក៖ អ៎ូ!

ខ៖ អត់ឱ្យធ្វើទេ អញឱ្យហែងរៀន។

ក៖ អ៎ូចឹងគាត់អត់បន្តវេនដល់កូន..?

ខ៖ បាទអត់។

ក៖ កូនចៅណាផង?

ខ៖ អត់មានឱ្យចេះទេរឿងជាងហោស។

ក៖ អ៎ូបាទកុងប៉ុន្តែ..?

ខ៖ ប៉ុននៅតែជាងដដែរបើនេះ បើដល់មិនឱ្យធ្វើជាងម៉េចធ្វើជាងឡាន។

ក៖ អ៎ូ!

ខ៖ រៀនធ្វើជាងឡាន។

ក៖ អ៎ូ! កុងរៀនជាងឡានហោសពីមុនកុង..?

ខ៖ អើសាលាទិចនិចហោសមិនរៀនជាង។

ក៖ បាទកុង!

ខ៖ សាលាជាងសាលាទិចនិចសាលាបឹងកុកហ្នឹងហោស។

ក៖ បាទកុងបាទ!

ខ៖ អើរៀនមានឯកទេស កាលណុងមើលជាងផ្សារមានជាងផ្សារជាងឡានជាងភ្លើង។

ក៖ បាទកុង!

ខ៖ ជាងរុំឌីណាម៉ូជាងរៀនតភ្លើងតអីហ្នឹងហាស។

ក៖ បាទកុងបាទ!

ខ៖ ហ្នឹងមានបីឯកទេសគេហាស។

ក៖ អ៎ូ!

ខ៖ ប៉ុនយកឯកទេសឡាន។

ក៖ អ៎ូបាទ!

ខ៖ បាទ!

ក៖ ចុះកុងគិតថាកាលពីក្មេងកុងធ្លាប់មានគោលបំណងថាធំឡើងកុងចង់ធ្វើអីមួយអត់កាលណុង?

ខ៖ បំណងខ្ញុំគ្មានទេមានតែធ្វើជាងហ្នឹង។

ក៖ អ៎ូចឹង..?

ខ៖ ប៉ុនឪពុកខ្ញុំហាសគាត់ថាចង់ឱ្យខ្ញុំធ្វើទាហ៊ានឪពុកខ្ញុំហាស។

ក៖ បាទកុង!

ខ៖ គាត់ថាចង់ឱ្យធ្វើទាហ៊ានហើយហ្នឹងគ្រូ។

ក៖ អ៎ូបាទកុង!

ខ៖ បាទ! ស្រាប់ដល់ខ្ញុំធំទៅថានេះពុកខ្ញុំបានធ្វើទាហ៊ានហោស។

ក៖ អ៎ូ!

ខ៖ បាត់មាត់ភ្លាមហាសដល់ស្រុកលន់នល់បែកទៅជំនាន់អាពតចប់មកដល់ជំនាន់លោកហ៊ុនសែនពុកខ្ញុំបានធ្វើគ្រូពុកខ្ញុំធ្វើគ្រូៗធ្វើគ្រូហើយ។

ក៖ អ៎ូ! បាទកុងបាទចុះអើចៅមានសំណួរចុងក្រោយមួយកុង បើសិនជាចង់ឱ្យកុងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយកុងមានពាក្យពេចន៍អីដែរចង់ផ្តាំទៅពួកគាត់អត់កុង?

ខ៖ បាទហ្នឹងហោស?

ក៖ បាទកុង!

ខ៖ អាហ្នឹងនិយាយប៉ះពាក្យតិចហើយ។

ក៖ បាទអត់អីទេកុង។

ខ៖ ចេះថាខ្ញុំធ្លាប់ឆ្លងកាត់ហាស។

ក៖ បាទ!

ខ៖ ជំនាន់សម្តេចឪសម្តេចឪលោកម្តងចេះហោសកូនចៅជំនាន់លោកលុនណុល លោកលុនណុលធ្វើអីធ្វើរដ្ឋាភិបាលស្រោចស្រងជាតិចឹងហាសណាស់។

ក៖ បាទកុង!

ខ៖ ឥឡូវយុវជនជំនាន់ហ្នឹងយុវជនស្រោចស្រងជាតិកូនចៅនៅអាយាគកុង។

ក៖ បាទកុង!

ខ៖ អើដល់កូនចៅនៅអាយាគកុងឪរត់ចេញពីស្រុក ចេញពីស្រុកទៅនៅចិនស្រែកឱ្យកូនចៅជនបទចូលព្រៃម៉ាគីប្រឆាំងជាមួយអាមេរិចកាំងប្រឆាំងជាមួយលន់នល់។

ក៖ អ៎ូបាទកុង!

ខ៖ អើឥឡូវឱ្យយុវជនឱ្យក្មេងជំនាន់ក្រោយគិតយ៉ាងម៉េច បើជំនាន់ខ្ញុំវាខកហើយណា៎។

ក៖ បាទកុងបាទ!

ខ៖ ឱ្យគ្នាធ្វើទាហ៊ានដេញអាយាគកុងដល់គ្នាធ្វើទាហ៊ានដេញអាយាគកុងខ្លួនឯងអាងខ្លួនឯងស្តេចរត់ទៅនៅចិនទៅនៅខាងយួនចូលព្រៃឱ្យប្រជាជនអ្នកណាស្រឡាញ់សម្តេចឪចូលព្រៃដូចអាវាយជាមួយចក្រព័ទ្ធលន់នល់។

ក៖ អ៎ូបាទ!

ខ៖ ហ្នឹងហើយបានដល់ពេលបារាំងចប់ជេរអ្នកថ្មីថាអាពួកចក្រព័ទ្ធពួកអាឈ្លើយសឹក។

ក៖ បាទកុងបាទ!

ខ៖ អើអាហ្នឹងបានន័យថាអ្នកទាំងអស់គ្នាមួយចំនួនអាហ្នឹងគេលាបពណ៌ហាសណា៎។

ក៖ បាទកុង!

ខ៖ គេលាបពណ៌ឱ្យដាច់ហាសអានេះសេរីអានេះកុម្មុនីសយ៍ អើដល់ខ្ញុំពីក្មេងពីតូចមកគេជេរខ្ញុំអាខ្មែរសេរីៗអើខៀវទៅចឹងតែម៉ងទៅ។

ក៖ អ៎ូ!

ខ៖ អើរួចលោកឪសម្តេចឪយើងនេះគាត់វែកជារាស្ត្រនេះឱ្យដាច់ហាសណា៎។

ក៖ បាទកុង!

ខ៖ អាណានៅទីក្រុងអាណាកាន់កាំភ្លើងលន់នល់ អាណុងលន់នល់ហើយណា៎។

ក៖ បាទកុងបាទ!

ខ៖ ពួកសេរីហាសណា៎។

ក៖ បាទ!

ខ៖ អើអ្នកណាស្នងដកដេកអើដេកព្រៃដេករណ្តៅអាណុងខាងរំដោះហាសណា៎។

ក៖ បាទកុងបាទ!

ខ៖ អើឃើញដៃរអាហ្នឹងហាស។

ក៖ អ៎ូ!

ខ៖ អើដល់ឥឡូវហ្នឹងម្នាក់ៗខ្លះសរសើរអ្នកនេះសរសើរអ្នកនោះយកខ្លួនឯងទៅៗដាក់ជាមួយគេឱ្យគេល្អអត់គិតខ្លួនឯង ខ្ញុំគិតថាខ្លួនទីពឹងខ្លួនខ្លួនគិតខ្លួនយើងមិនបាច់គិតអាណា។

ក៖ បាទកុងបាទ!

ខ៖ អើទៅជឿហ្នឹងហាស ឥឡូវបើឥឡូវអ្នកអស់ណុងអ្នកខ្លះអ្នលក្រពីដើមហាសខ្ញុំទៅសួងខ្ញុំឃើញហើយ បងប្អូនថាញាតិចុះឪពុកគាត់ធ្វើប៉ូលីសប៉ាវក្រហមទាល់តែខាត់ឥឡូវកូនមួយឆ្លូតកូនមួយមេម៉ាយក្រ រួចពីដើមហាសជំនាន់ណុងហាសសុទ្ធផ្ទះក្បឿងហាស រួចកាលណុងអីសម្តេចឪហាស ជយោសម្តេចឪហាសណា៎ ឥឡូវសម្តេចឪមកធ្វើផ្ទះក្បឿងឱ្យមកវិញទេ ដល់ខ្ញុំ

និយាយទៅអាក្រក់ឥឡូវអើគ្រាន់ថាចឹងបានខ្ញុំខ្លាចដល់អាខ្លះថាអួតចុះអួតឡើងអញ អញ៧៩ ដែរតើ ប៉ុនអញមិនធ្វើទាហ៊ានអញធ្វើគ្រូហាសអញជួយហែងអស់ប៉ុណ្ណឹងហើយថាអញអាក្រក់ទៀតហាស។

ក៖ អ៎ូ!

ខ៖ មានអីមានតែហែង។

ក៖ បាទអ៎ូ!

ខ៖ ក្តៅចិត្តដល់នោះថាចឹងមានតែហែងអញ់អត់ពងទេចឹង។

ក៖ បាទកុងបាទ!

ខ៖ ចឹងហាសចឹងបានថាមិនបាច់គិតអីច្រើនទេ គិតខ្លួនយើងដោះស្រាយខ្លួនយើងអ្នកឯងម៉េចទៅយើងកុំឱ្យខុសច្បាប់។

ក៖ បាទ!

ខ៖ កុំឱ្យតែបំពានគេកុំឱ្យតែគេវេទនាដោយសារខ្លួនយើង។

ក៖ បាទកុងបាទត្រូវ!

ខ៖ ប៉ុនបើយើងធ្វើល្អទុកទៅឱ្យគេមើលយើងទៅ។

ក៖ បាទ!

ខ៖ បាទ អាក្រក់កុំកាន់កុំប៉ះកុំពាល់។

ក៖ បាទកុងបាទចឹងប្រហែលជាកុងមានប៉ុណ្ណឹងទេណោះកុងណោះ?

ខ៖ បាទ!

ក៖ ចឹង..?

ខ៖ ចឹងឥឡូវសព្វថ្ងៃអ្នកខ្លះស្អីៗសមរង្សីមកហើយសមរង្សីមកហើយមានតែមួយហ្នឹងទេអើយ អាហ្នឹងដូចសម្តេចឪជំយោសម្តេចឪ សម្តេចឪមកចប់ហើយលែងសង្គ្រាមហើយអើលែងចុះ សម្តេចឪមកនៅតែកាប់គ្នាដដែរណុង បាទអាណុងមកនៅតែកាប់គ្នាដដែរតាមមើលជឿទេ។

ក៖ អ៎ំបាទកុងបាទ!

ខ៖ ជឿទេ។

ក៖ ត្រូវកុងត្រូវ!

ខ៖ ឥឡូវបើមកមកមិនកាប់គ្នាទៀតលើសដើម។

ក៖ បាទកុងត្រូវ!

ខ៖ ខ្ញុំមិនកាន់ជើងខាងណាប៉ុនចឹងបើសិនខ្លួនយើងមានបាយបើការរកស៊ីមានប្រាក់ខែមានលុយមានកាក់ទិញអង្ករដាំបាយស៊ីស្រួលទេ។

ក៖ បាទកុង!

ខ៖ កុំទៅលេងល្បែងកុំទៅជំពាក់គេរួចគ្នាបាត់។

ក៖ បាទត្រូវកុងត្រូវកុង៕